អង្គការស្បៀង
អាហារ និង កសិកម្ម
នៃសហប្រជាជាតិ

FAO
សេចក្តីណែនាំបច្ចេកទេស
ដើម្បីភាពទទួលខុសត្រូវ
វិស័យជលផល
៥



# ការអភិវឌ្ឍវារីវប្បកម្ម

FAO
សេចក្ដីណែនាំបច្ចេកទេស
ដើម្បីភាពទទួលខុសត្រូវ
វិស័យជលផល

# ការអភិវឌ្ឍវារីវប្បកម្ម

ម.ព.ឯ.ក AIDOC
Code: 137-008
Date:
Donated by:

អង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិ
ទីក្រុងរ៉ូម ឆ្នាំ១៩៩៧

FAO

អង្គការស្បៀង
អាហារ និង កសិកម្ម
នៃសហប្រជាជាតិ

សេចក្តីណែនាំបច្ចេកទេស
ដើម្បីភាពទទួលខុសត្រូវ
វិស័យជលផល

៥

# ការអភិវឌ្ឍវារីវប្បកម្ម


សហការផលិតដោយ
នាយកដ្ឋានជលផល និង JICA ខែវិច្ឆិកា ២០០៣
ឧបត្ថម្ភថវិកាដោយ JICA

ការរៀបចំដែលបានធ្វើឡើង និង អត្ថន័យនៃអត្ថបទទាំងមូលដែលបានបោះពុម្ពផ្សាយនេះពុំមែនឆ្លុះបញ្ចាំងទស្សនៈ ទោះជានៅក្នុងផ្នែកណាមួយរបស់អង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិលើការងារច្បាប់របស់ប្រទេស ដែនដី ទីក្រុង តំបន់ ឬ លើការងារគ្រប់គ្រងនៃអាជ្ញាធរផ្ទាល់ ឬ ពាក់ព័ន្ធទៅនឹងការកំណត់តំបន់ដែលត្រូវគ្រប់គ្រងឡើយ ។

រក្សាសិទ្ធគ្រប់យ៉ាងដោយនាយកដ្ឋានជលផល ។ គ្មានផ្នែកណាមួយនៃឯកសារនេះត្រូវបានបោះពុម្ពចំលងឡើងវិញ រក្សាទុកក្នុងប្រព័ន្ធដែលរកបានមក ឬ បញ្ជូនទៅវិញទៅមកតាមរូបភាព ឬ ដោយមធ្យោបាយណាមួយដូចជា: អេឡិចត្រូនិច មេកានិច ថតចំឡង ឬ មធ្យោបាយផ្សេងទៀតដែលមិនបានសុំការអនុញ្ញាតពីអ្នករក្សាសិទ្ធិជាមុនឡើយ ។ រាល់ការស្នើសុំត្រូវភ្ជាប់មកជាមួយនូវគោលបំណង និង វិសាលភាពនៃការបោះពុម្ពឡើងវិញត្រូវតែផ្ញើមកនាយកដ្ឋានជលផល អាសយដ្ឋានលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារលេខ (៨៥៥) ២៣ ២១៥ ៤៧០ ប្រអប់សំបុត្រលេខ ៥៨២ ។

© ជ.ផ ២០០៣

បកប្រែសម្រួល និង បោះពុម្ពឡើងវិញ ឆ្នាំ ២០០៣

បកប្រែសម្រួលដោយ
- លោក ម៉ៅ សំអុន
- លោក ហាវ វិសិដ្ឋ

ពិនិត្យកែសម្រួលដោយ
- លោក ណៅ ធូក
- លោក សម នៅ

ការអភិវឌ្ឍវារីវប្បកម្មដែលឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ប្អូនៗ សិស្សានុសិស្ស និង មិត្តរួមអាជីពទាំងអស់កំពុងកាន់អាននៅក្នុងដៃនេះត្រូវបានបកប្រែសម្រួល រៀបរៀង ចងក្រង ហើយបោះពុម្ពយ៉ាងសម្រិតសម្រាំងចេញពីសៀវភៅជាភាសាអង់គ្លេសដែលមានចំណងជើងថា " Aquaculture Development " ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍវិស័យវារីវប្បកម្មរបស់ប្រទេសជាតិក្នុងដំណាក់កាលបច្ចុប្បន្ន ។

ការអភិវឌ្ឍវារីវប្បកម្មត្រូវបានបកប្រែមកជាភាសាជាតិការប្រើពាក្យពេចន៍ទាំងអស់ដែលមាននៅក្នុងសៀវភៅនេះគឺផ្អែកទៅតាមវចនានុក្រមខ្មែរដែលជាការចេញផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១១ គ.ស. ១៩៦៧ ។

ចំពោះខ្លឹមសារបច្ចេកទេសដែលមាននៅក្នុងសៀវភៅទាំងមូល យើងខ្ញុំបានពិនិត្យកែសំរួលផ្ទៀងផ្ទាត់ សាចុះសាឡើងជាច្រើនលើក ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ យើងខ្ញុំជឿជាក់ថាពិតជានៅមានខ្វះចន្លោះខ្លះៗជាមិនខាន ទោះបីដោយចេតនា ឬ អចេតនាក្តី ។

យើងខ្ញុំទាំងអស់គ្នារង់ចាំទទួលរាល់ការរិះគន់ ស្តាប់នាពីសំណាក់អ្នកអានគ្រប់មជ្ឈដ្ឋានដោយសេចក្តីសោមនស្សរីករាយ ។

រាល់មតិ យោបល់រិះគន់កែលំអដើម្បីស្តាប់នាទាំងអស់ សូមផ្ញើមកនាយកដ្ឋានជលផលលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៥៨២ ឬ តាមរយៈ e-mail: nuov@mobitel.com.kh ។

## ការរៀបចំឯកសារ

សេចក្តីណែនាំនេះបានរៀបចំឡើងដោយនាយកដ្ឋានជលផល ឧបត្ថម្ភថវិកាដោយ JICA មតិ និង សំណូមពរនានាដែលមានក្នុងសេចក្តីណែនាំសំរាប់ការអភិវឌ្ឍវិស័យជលផលដែលប្រកបដោយភាពទទួលខុសត្រូវសំរាប់ជាព័ត៌មានដើម្បីប្រឹក្សាបច្ចេកទេស ស្តីពីក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងការធ្វើអាជីវកម្មនេសាទ នៅទីក្រុងរ៉ូម ពីថ្ងៃទី២៦ ខែកញ្ញា ដល់ ថ្ងៃទី ៥ ខែតុលា ឆ្នាំ១៩៩៤។ ក្នុងសេចក្តីបញ្ចប់នៃឯកសារនេះមានការយកចិត្តទុកដាក់ផ្តោតទៅលើមតិ និង សំណូមពរបន្ថែមនានាដែលទទួលបាន និង ដើម្បីភ្ជាប់ទៅនឹងទស្សនៈផ្សេងៗរបស់ជំនាញការនៅក្នុងបណ្តាកិច្ចប្រជុំអន្តរជាតិសំខាន់ៗ និង/ឬ ការបោះពុម្ពផ្សេងៗ ។ ឯកសារនេះត្រូវបានរៀបចំក្រោមការសំរបសំរួលរបស់ R.L. Welcomme និង U.Barg ស្តីពីធនធានទឹកសាប និង វារីវប្បកម្ម និង មានបន្ថែមបទពិសោធន៍ដែលទទួលបានពីបុគ្គលិកដែលធ្លាប់បានធ្វើការពាក់ព័ន្ធទៅនឹងនិន្នាការ និង ការអភិវឌ្ឍនានាដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងវិស័យវារីវប្បកម្ម។ លោក M. Lizarraga, A. Van Houtte, C. Leria, W. Edeson, K.grainger, A. Bonzon, D. Greboval, E. Ruckes, C. Lima Dos Santos, J. Kapetsky, H. Naeve, Z. Shehadeh, D. Bartley, R. Subasinghe, A. Tacon និង F. Henderson បានជួយ និង ចូលរួមចំណែកក្នុងកិច្ចខិតខំនេះតាមគ្រប់វិធី ។

គួរកត់សំគាល់ថា សេចក្តីណែនាំទាំងនេះមិនស្ថិតនៅក្នុងស្ថានភាពស្របច្បាប់ទេ ។ វាគឺជាការបំរុងទុកផ្តល់ជាជំហានទូទៅដើម្បីឧបត្ថម្ភគាំទ្រដល់ការអនុវត្តមាត្រា៩( ការអភិវឌ្ឍវារីវប្បកម្ម) នៃក្រមប្រតិបត្តិដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល ។ ឯកសារនេះផ្តល់ដល់អ្នកអាននូវការកត់សំគាល់តាមបែបទូទៅ និង ជាមធ្យោបាយដើម្បីបំរើឱ្យការណែនាំទូទៅ ហើយគួរចាត់ទុកដូចជាការផ្តល់យោបល់ ឬ ការអង្កេតដើម្បីយកចិត្តទុកដាក់ នៅពេលប្រឈមមុខនឹងបញ្ហាដែលពាក់ព័ន្ធទៅនឹងការអនុវត្តកថាខណ្ឌនានារបស់ក្រមប្រតិបត្តិដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល ។ ម្យ៉ាងទៀតភាពខុសគ្នាជាយថាហេតុក្នុងការប្រើពាក្យបច្ចេកទេសគួរតែបានយល់ថាគឺជាការបកប្រែសំរួលឡើងវិញរបស់ក្រមប្រតិបត្តិ ។ គួរចងចាំបន្ថែមថា សេចក្តីណែនាំបានត្រៀមបំរុងដើម្បីអាចបត់បែន និង សមត្ថភាពផ្លាស់ប្តូរទៅតាមកាលៈទេសៈនៅពេលដែលមានការប្រែ

ប្រួលផ្សេងៗ ឬ ព័ត៌មានថ្មីៗដែលប្រែក្លាយទៅជាមានប្រយោជន៍ ។ សេចក្តីណែនាំនេះអាចកែសំរួល ហើយបំពេញបន្ថែមដោយសេចក្តីណែនាំ និង កំណត់ត្រាដទៃទៀត... ។ល។ លើបញ្ហាជាក់ស្តែងហើយ មួយចំនួនបានស្ថិតក្រោមការបរិយាយយ៉ាងល្អិតល្អន់ដូចបានចង្អុលបង្ហាញក្នុងអត្ថបទនៃឯកសារនេះ ។ ចំពោះបញ្ហានេះ សូមអញ្ជើញអ្នកអានទាំងអស់ចូលរួមសហការជាមួយ FAO ផ្តល់ព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធបច្ចេកទេស គោលនយោបាយ និង បញ្ហាផ្សេងៗស្របច្បាប់ដែលអាចជាប្រយោជន៍ក្នុង ការកែលំអឱ្យទាន់សម័យ វាយតំលៃ និង ធ្វើឱ្យប្រសើរឡើងនូវឯកសារនេះ ដូចជាក្នុងការអភិវឌ្ឍ ឱ្យបានជាក់ស្តែងជាងនូវឯកសារណែនាំសំដៅជំរុញអភិវឌ្ឍវារីវប្បកម្មឱ្យប្រកបដោយភាពទទួលខុស ត្រូវដើម្បីចូលរួមវិភាគទានក្នុងការផ្គត់ផ្គង់ម្ហូបអាហារប្រកបដោយនិរន្តរភាព ។

**ការចូលរួមចំណែក :**

- គ្រប់សមាជិក FAO និង សមាជិកជាសហការីទាំងអស់ដែលបានចាប់អារម្មណ៍ អង្គការជាតិ និង អន្តរជាតិទាំងអស់
- នាយកដ្ឋានជលផលរបស់FAO
- ប្រធានការិយាល័យជលផលនៃFAO ក្នុងការិយាល័យថ្នាក់តំបន់ទាំងអស់របស់FAO
- អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលបានចាប់អារម្មណ៍

នាយកដ្ឋានជលផលរបស់FAO
ការអភិវឌ្ឍវារីវប្បកម្ម
សេចក្តីណែនាំបច្ចេកទេសរបស់FAO ដើម្បីភាពទទួលខុសត្រូវក្នុងវិស័យជលផល លេខ៥
ទីក្រុងរ៉ូមFAO ឆ្នាំ១៩៩៧ ៤០ ទំព័រ ។

__សង្ខេប__

វារីវប្បកម្មគឺជាវិស័យមួយដែលរីកចំរើនរហ័សបំផុតក្នុងប្រព័ន្ធផលិតកម្មម្ហូបអាហារលើពិភព លោកជាមួយនឹងបន្ទុកនៃលទ្ធផលបច្ចុប្បន្នដែលបានផលិតក្នុងបណ្តាប្រទេសកំពុងរីកចំរើន ហើយ សង្ឃឹមជឿជាក់របស់វារីវប្បកម្មដើម្បីចូលរួមចំណែកក្នុងសុវត្ថិភាពស្បៀង និង កាត់បន្ថយភាពក្រី ក្រ ។ ការអនុវត្តវារីវប្បកម្មភាគច្រើននៅជុំវិញពិភពលោកបានប្រព្រឹត្តទៅជាមួយនឹងផលប្រយោជន៍

សំខាន់នៃម្ហូបអាហារ និង សង្គម ហើយជាទូទៅជាមួយនឹងតំលៃបរិស្ថានតិចតួច ឬ គ្មានសោះ ។ ប៉ុន្តែវាមានសារៈសំខាន់ណាស់សំរាប់គោលដៅនៃកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នសំរាប់ជោគជ័យវិស័យវារីវប្បកម្មនៅថ្ងៃអនាគតទាំងបណ្តាប្រទេសកំពុងអភិវឌ្ឍ និង ប្រទេសអភិវឌ្ឍ បណ្តាសក្តានុពលសង្គម និង បរិស្ថានគឺជាកត្តាដែលត្រូវបានគិតគូរយ៉ាងត្រឹមត្រូវសំរាប់ធានាថាការអភិវឌ្ឍវារីវប្បកម្មប្រកបដោយស្ថេរភាព ។

ឯកសារនេះផ្តល់ការបកស្រាយពន្យល់ឆ្លើយតបទៅនឹងគោលការណ៍នៃមាត្រា ៩ របស់ក្រមប្រតិបត្តិប្រកបដោយការទទួលខុសត្រូវក្នុងវិស័យជលផល ។ ការបកស្រាយទាំងនេះគឺជាមធ្យោបាយសំរាប់ប្រើប្រាស់ជាការណែនាំទូទៅ ហើយគួរតែទទួលបានយកមកវិញនូវសំណូមពរ ឬ ការអង្កេតបំរុងទុកសំរាប់ជួយជាប្រយោជន៍ក្នុងការកំណត់លក្ខណៈវិនិច្ឆ័យ និង ការជ្រើសរើសសំរាប់សកម្មភាពរបស់គេក្នុងភាពជាដៃគូរដើម្បីសហការណ៍គាំទ្រការអភិវឌ្ឍវារីវប្បកម្មដែលប្រកបដោយនិរន្តរភាព ។

ភាពផ្សេងគ្នានៃវារីវប្បកម្ម ហើយ ពេលខ្លះការយល់ដឹងពី ស្ថេរភាព តុល្យភាព និង ព័ត៌មានជាច្រើនទៀតត្រូវការជាចាំបាច់ដើម្បី ប្រឈមមុខនឹងញ្ហាការអភិវឌ្ឍ និង បរិស្ថាននៅទីកន្លែងជាក់ស្តែងណាមួយ ។ ការប្តេជ្ញាចិត្តដើម្បីធ្វើកិច្ចសហការការសន្ទនាដែលមានប្រយោជន៍រវាងបណ្តាដៃគូរដែលមានការទទួលខុសត្រូវ និង ការចូលរួមរបស់វារីវប្បករ និង សហគមន៍របស់គេគឺជាការចាំបាច់នៅពេលដែលមានការបែងចែកការទទួលខុសត្រូវសំរាប់និរន្តរភាពនៃការអភិវឌ្ឍវារីវប្បកម្ម ។

បង្គលក្ខខណ្ឌងាយស្រួលឱ្យសំរេចទៅបានសំរាប់ការអភិវឌ្ឍវារីវប្បកម្មក្របដោយនិរន្តរភាពគឺជាការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ រដ្ឋាភិបាល និង ស្ថាប័ន សង្គម និង បណ្តាអ្នកវិទ្យាសាស្រ្ត សារព័ត៌មាន ស្ថាប័នហិរញ្ញវត្ថុ បណ្តាក្រុមដែលទទួលផលប្រយោជន៍ពិសេស រាប់បញ្ចូលទាំងបណ្តាវិស័យឯកជន និង សង្គមពាក់ព័ន្ធរបស់គេដូចជា: វារីវប្បករនៃវារីវប្បកម្ម ផលិតករ និង អ្នកផ្គត់ផ្គង់ អ្នកកែច្នៃ និង ពាណិជ្ជករនៃផលិតផលវារីវប្បកម្ម ។ ការប្តេជ្ញាចិត្តស្វែងយល់ត្រឹមត្រូវ និង ឥរិយាបថទទួលខុសត្រូវក្នុងការប្រឹក្សាយោបល់ និង ការចចាររវាងបណ្តាប្រទេស ឬ តំបន់នឹងជួយការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាពផងដែរ ។

មាតិកា ទំព័រ


សាវតារ ១

១. សេចក្តីផ្តើម ៥

២.ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវរាប់បញ្ចូលទាំងវារីវប្បកម្ម ផ្អែកលើផលផលនៅក្នុងតំបន់ដែលស្ថិតក្រោមយុត្តាធិការជាតិ ១២

៣.ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវរាប់បញ្ចូលទាំងវារីវប្បកម្មផ្អែក លើផលផលក្នុងក្របខណ្ឌដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីនៃវារីសត្វ និង រុក្ខជាតិ ២៥

៤.ការប្រើប្រាស់ប្រភពវារីសេនេទិចសំរាប់គោលបំណងនៃវារីវប្បកម្មរាប់បញ្ចូលទាំង វារីវប្បកម្មផ្អែកលើផលផល ៣៣

៥. វារីវប្បកម្មដែលប្រកបដោយភាពទទួលខុសត្រូវក្នុងផលិតកម្ម ៤១

៦. ឯកសារបង្អែក ៥៤

សាវតារ

១. តាំងពីសម័យបុរាណ ការធ្វើអាជីវកម្មនេសាទត្រូវបានចាត់ទុកថាជាប្រភពមួយផ្ដល់ម្ហូបអាហារមួយយ៉ាងសំខាន់សំរាប់មនុស្សជាតិ ប្រភពផ្ដល់ការងារ និង មានសារៈប្រយោជន៍សេដ្ឋកិច្ចដល់អ្នកដែលចូលរួមក្នុងសកម្មភាពនេះ។ ប៉ុន្តែជាមួយនឹងការកើនឡើងនៃចំណេះដឹង និង ចំរើនវឌ្ឍនៃការអភិវឌ្ឍវិស័យជលផលត្រូវបានគេដឹងថាប្រភពវារីសត្វ និង រុក្ខជាតិដែលកំពុងរស់នៅ ទោះបីអាចធ្វើឱ្យមានដូចដើមវិញក៏ដោយ ចាំបាច់ត្រូវតែមានការគ្រប់គ្រងឱ្យបានសមស្រប ប្រសិនបើការចូលរួមវិភាគទានក្នុងសេដ្ឋកិច្ច អាហារូបត្ថម្ភ និង សុខុមាលភាពសង្គមនៃការរីកចំរើនប្រជាពលរដ្ឋលើពិភពលោកត្រូវបានគាំទ្រ ។

២. ការយល់ព្រមទទួលស្គាល់សន្និសីទនៃសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ក្នុងឆ្នាំ ១៩៨២ បានផ្ដល់នូវរចនាសម្ព័ន្ធថ្មី ដើម្បីគ្រប់គ្រងប្រភពធនធានសមុទ្រឱ្យបានកាន់តែប្រសើរជាងមុន។ របបគ្រប់គ្រងមហាសាគរថ្មីត្រឹមត្រូវតាមច្បាប់បានផ្ដល់សិទ្ធិ និង ការទទួលខុសត្រូវឆ្នេរសមុទ្ររបស់ប្រទេសដើម្បីគ្រប់គ្រង និង ប្រើប្រាស់ធនធានជលផលនៅក្នុងក្របខ័ណ្ឌនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខដែលរួមបញ្ចូលប្រហែល ៩០% នៃវិស័យជលផលទឹកប្រៃពិភពលោក។

៣. ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ជលផលពិភពលោកបានប្រែក្លាយជាវិស័យមួយដែលកំពុងអភិវឌ្ឍប្រកបដោយចំរើនវឌ្ឍនៃឧស្សាហកម្មម្ហូបអាហារ ហើយប្រទេសជាច្រើនបានខិតខំយ៉ាងខ្លាំងដើម្បីប្រមូលយកផលប្រយោជន៍ពីឱកាសថ្មីរបស់គេដោយវិនិយោគទុនទៅលើនាវានេសាទទំនើបៗ និង រោងចក្រកែច្នៃ ដើម្បីឆ្លើយតបទៅនឹងតំរូវការកើនឡើងរបស់ត្រី និង ផលិតផលត្រីពីសំណាក់អន្តរជាតិ។ ជាការពិតណាស់ ប្រភពធនធានជាច្រើនមិនអាចទ្រទ្រង់បានទេ ពេលខ្លះមិនទាំងអាចត្រួតពិនិត្យបាននូវកំណើននៃការធ្វើអាជីវកម្មបានផង ។

៤. សញ្ញាយ៉ាងច្បាស់ជាច្រើននៃការធ្វើអាជីវកម្មលើសហួសកំរិតទៅលើសន្និធិត្រីសំខាន់ៗ ការកែប្រែប្រព័ន្ធអេកូឡូស៊ីការបាត់បង់ភាពសំខាន់នៃសេដ្ឋកិច្ចនិងបណ្ដាវិវាទអន្តរជាតិលើកការគ្រប់គ្រង និង ការធ្វើពាណិជ្ជកម្មត្រីបានគំរាមកំហែងដល់និរន្តរភាព និង ការចូលរួមវិភាគទាននៃវិស័យជលផលក្នុងការផ្គត់ផ្គង់ម្ហូបអាហារសំរាប់រយៈពេលយូរអង្វែង ។

នៅសម័យប្រជុំលើកទី១៩ របស់គណៈកម្មាធិការជលផលនៃFAO ដែលបានប្រព្រឹត្តិទៅកាលពីខែមីនា ឆ្នាំ១៩៩១បានសំណូមពរថាៈ បញ្ហាថ្មីៗ ក្នុងការងារគ្រប់គ្រងវិស័យជលផលកំពុងតែបញ្ចូលការអភិរក្ស និង បរិស្ថានដូចជាការយកចិត្តទុកដាក់ទៅលើសង្គម និងសេដ្ឋកិច្ចគឺជាការចាំបាច់បន្ទាន់។ FAOបានស្នើឱ្យបង្កើតគំនិតដែលប្រកបដោយភាពទទួលខុសត្រូវជលផលនិងបរិយាយយ៉ាងល្អិតល្អន់នូវខ្លឹមសារនៃក្រមប្រតិបត្តិ ដើម្បីជំរុញឱ្យមានការអនុវត្តកាន់តែទូលំទូលាយ ។

៥.រដ្ឋាភិបាលនៃប្រទេសម៉ិចសិចកូសហការជាមួយ FAOបានរៀបចំសន្និសីទអន្តរជាតិស្តីពីការទទួលខុសត្រូវក្នុងអាជីវកម្មនេសាទនៅCancun ខែមីនា ឆ្នាំ១៩៩២។ សេចក្តីប្រកាសនៅ Cancun ដែលយល់ព្រមនៅក្នុងសន្និសីទបានពាំនាំនូវការចាប់អារម្មណ៍ សង្ខេបរបស់ UNCED នៅ Rio de Janeiro, ប្រេស៊ីល ខែមិថុនា ឆ្នាំ១៩៩២ ដែលបានគាំទ្រនូវការរៀបចំក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល។ ការប្រឹក្សាយោបល់បច្ចេកទេស FAO ស្តីពីការធ្វើអាជីវកម្មក្នុងលំហសមុទ្រក្រៅដែលបានប្រព្រឹត្តិទៅនៅ ខែ កញ្ញា ឆ្នាំ១៩៩២ បានធ្វើអនុសាសន៍បរិយាយយ៉ាងល្អិតល្អន់ទៅលើក្រមប្រតិបត្តិ ដើម្បីប្រឈមមុខចំពោះបញ្ហាដែលពាក់ព័ន្ធជលផលក្នុងលំហសមុទ្រក្រៅ ។

៦.សម័យប្រជុំលើកទី ១០២នៃក្រុមប្រឹក្សាFAO បានប្រារព្ធឡើងកាលពីខែ វិច្ឆិកា ឆ្នាំ១៩៩២ បានពិភាក្សាយ៉ាងលំអិតទៅលើក្រមប្រតិបត្តិ សំណូមពរថាត្រូវផ្តល់អត្ថិភាពទៅឱ្យបញ្ហាដែលពាក់ព័ន្ធក្នុងលំហសមុទ្រក្រៅហើយបានស្នើថា បណ្តាសំណើសំរាប់ក្រមប្រតិបត្តិត្រូវតែធ្វើឱ្យហើយនៅក្នុងសម័យប្រជុំគណៈកម្មាធិការជលផល ឆ្នាំ១៩៩៣ ។

៧.សម័យប្រជុំលើកទី ២០របស់COFI ប្រារព្ធធ្វើឡើងនៅខែមីនា ឆ្នាំ១៩៩៣ បានត្រួតពិនិត្យជាទូទៅលើសំណើរចនាសម្ព័ន្ធ និង មាតិកានៃក្រមប្រតិបត្តិដែលរាប់បញ្ចូលទាំងការបកស្រាយលំអិតនៃសេចក្តីណែនាំ និង យល់ព្រមពីពេលវេលាសំរាប់ការបកស្រាយពន្យល់ក្រមប្រតិបត្តិ។ សម័យប្រជុំក៏បានស្នើឱ្យ FAO រៀបចំផងដែរនូវផ្នែកមួយនៃក្រមប្រតិបត្តិមូលដ្ឋានសំរាប់តាមដានឱ្យបានរហ័សការស្នើសុំដើម្បីទប់ស្កាត់ការដោតទង់ជាតិឡើងវិញរបស់នាវានេសាទដែលជាកត្តាជះឥទ្ធិពលដល់ការអភិរក្ស និង វិធានការគ្រប់គ្រងនៅលើលំហសមុទ្រ ។ លទ្ធផលនៃសន្និសីទរបស់ FAO នៅក្នុងសម័យប្រជុំលើកទី ២៧ ខែវិច្ឆិកា ១៩៩៣ ហើយទទួលយកនូវកិច្ចសន្យា ដើម្បីជំរុញឱ្យប្រព្រឹត្តិតាម

ការអភិរក្ស និង វិធានការគ្រប់គ្រងអន្តរជាតិដោយនាវានេសាទនៅលើលំហសមុទ្រក្រៅបង្កើតបានជាផ្នែកមួយនៃក្រមប្រតិបត្តិដែលផ្អែកតាមដំណោះស្រាយសន្និសីទ ១៥/៩៣ ។

៨. ក្រមប្រតិបត្តិបានបង្កើតឡើង ដើម្បីបកប្រែពន្យល់ និង អនុវត្តអនុលោមទៅតាមក្បួនខ្នាតដែលពាក់ព័ន្ធច្បាប់អន្តរជាតិ ដូចបានឆ្លុះបញ្ចាំងនៅក្នុងសន្និបាតនៃអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ហាក់បីដូចជាកិច្ចសន្យាមួយ ដើម្បីអនុវត្តនូវកថាខណ្ឌនានានៃសន្និបាតអង្គការសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ ១០ធ្នូ ឆ្នាំ១៩៨២ ពាក់ព័ន្ធទៅនឹងការអភិរក្ស និង ការគ្រប់គ្រងសន្និធិត្រី និង សន្និធិត្រីដែលមានបំលាស់ទីឆ្ងាយឆ្នាំ១៩៩៥និងជាពន្លឺនៃសេចក្តីប្រកាសរបស់Cancun នៅRio ឆ្នាំ១៩៩២ ស្តីពីបរិស្ថាន និង ការអភិវឌ្ឍជាពិសេសក្នុងជំពូក១៧ នៃរបៀបវារៈទី ២១ ។

៩.ការរៀបចំក្រមប្រតិបត្តិបានអនុវត្តដោយ FAO ក្នុងការពិភាក្សា និង សហការជាមួយបណ្តាភ្នាក់ងារសហប្រជាជាតិពាក់ព័ន្ធ និងអង្គការអន្តរជាតិនានារាប់បញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាលនានា ។

១០. ក្រមប្រតិបត្តិរួមមាន ៥មាត្រា: ចរិត ទំហំ និង គោលបំណង ការទាក់ទងជាមួយនឹងស្ថាប័នអន្តរជាតិផ្សេងទៀត ការអនុវត្ត ត្រួតពិនិត្យ ហើយធ្វើឱ្យទាន់សម័យ និងសំណូមពរពិសេសនៃបណ្តាប្រទេសកំពុងអភិវឌ្ឍ ។ មាត្រាផ្តើមទាំងអស់គឺអនុលោមទៅតាមមាត្រាមួយ ស្តីពីគោលការណ៍ទូទៅដែលមានចែងក្នុងកថាខណ្ឌទាំង ៦ នៃការគ្រប់គ្រងជលផល ដំណើរការអាជីវកម្ម ការអភិវឌ្ឍវារីវប្បកម្ម ការធ្វើសមាហរណកម្មវិស័យជលផលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ការងារប្រតិបត្តិក្រោយពេលប្រមូលផល និង ពាណិជ្ជកម្មនិងការស្រាវជ្រាវជលផល ។ ដូចបានលើកឡើងខាងដើម កិច្ចព្រមព្រាង ដើម្បីជំរុញការអនុវត្តជាមួយនឹងការអភិរក្ស និង ការគ្រប់គ្រងអន្តរជាតិ ដោយវាស់ស្ទង់នាវានេសាទនៅលើលំហសមុទ្រក្រៅបង្កើតឡើងជាផ្នែកមួយនៃក្រមប្រតិបត្តិទាំងមូល ។

១១. ក្រមប្រតិបត្តិគឺជាការស្ម័គ្រចិត្ត ប៉ុន្តែផ្នែកខ្លះដែលបានកំណត់ហើយគឺ ផ្អែកលើវិធាននៃច្បាប់អន្តរជាតិ ដូចបានឆ្លុះបញ្ចាំងក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ នៅថ្ងៃទី ១០ ធ្នូ ឆ្នាំ១៩៨២ ។ ក្រមប្រតិបត្តិក៏មានផ្ទុកផងដែរនូវខមួយចំនួនដែលអាច ឬ បានចូលជាធរមានដោយមធ្យោបាយនៃឧបករណ៍ច្បាប់ផ្សេងទៀតដែលស្របច្បាប់ក្នុងចំណោមភាគី ដូចកិច្ចព្រមព្រាងដើម្បី

ជំរុញការអនុវត្តតាមការអភិរក្ស និងការគ្រប់គ្រងអន្តរជាតិដែលរាស់ស្ទង់ដោយនាវាទេសាចរលើសំហសមុទ្រក្រៅ ឆ្នាំ១៩៩៣ ។

១២. សម័យប្រជុំលើកទី ២៨ នៃសន្និសីទក្នុងដំណោះស្រាយ ៤/៩៥ បានទទួលយកក្រមប្រតិបត្តិប្រកបដោយការទទួលខុសត្រូវក្នុងវិស័យជលផល ថ្ងៃទី ៣១ តុលា ឆ្នាំ១៩៩៥។ ដំណោះស្រាយដូចគ្នាបានស្នើសុំឱ្យFAOបរិយាយល្អិតល្អន់នូវសេចក្តីណែនាំបច្ចេកទេសសមស្របក្នុងការគាំទ្រការអនុវត្តក្រមប្រតិបត្តិដោយសហការជាមួយនឹងបណ្តាសមាជិក និង ស្ថាប័នដែលទទួលផលប្រយោជន៍ពាក់ព័ន្ធ។

## ១. សេចក្តីផ្តើម

### ១.១ បរិបទ និង ទំហំ

"ប្រទេសសនានាគួរតែយកចិត្តទុកដាក់លើវារីវប្បកម្ម រាប់បញ្ចូលទាំងវារីវប្បកម្មផ្អែកលើជលផល ដូចជាមធ្យោបាយដើម្បីជំរុញឱ្យមានប្រាក់ចំណូល និង អាហារកាន់តែច្រើនឡើង ។ ម្ល៉ោះហើយ ប្រទេសទាំងនោះត្រូវតែធានាឱ្យបានច្បាស់ថា ធនធានត្រូវបានប្រើប្រាស់ប្រកបដោយភាពទទួលខុសត្រូវហើយផលប៉ះពាល់ទៅលើបរិស្ថាន និង សហគមន៍មូលដ្ឋានត្រូវតែនៅកំរិតអប្បបរមា" ។

*មាត្រា ៦.១៩*
*គោលការណ៍ទូទៅ*
*ក្រមប្រតិបត្តិប្រកបដោយការទទួលខុសត្រូវក្នុងវិស័យជលផល*

បច្ចុប្បន្នវារីវប្បកម្មគឺជាវិស័យមួយដែលរីកចំរើនលូតលាស់យ៉ាងរហ័សបំផុតក្នុងប្រព័ន្ធផលិតម្ហូបអាហារលើពិភពលោក ។ មួយភាគធំនៃផលិតផលវារីវប្បកម្មពិភពលោកគឺផលិតក្នុងបណ្តាប្រទេសកំពុងរីកចំរើន ហើយមានសារៈសំខាន់ណាស់ក្នុងបណ្តាប្រទេសដែលមានចំណូលទាប និង ឱនភាពម្ហូបអាហារ ។ ជាមួយនឹងទិន្នផលមិនច្បាស់លាស់ដែលបានពីបណ្តាអាជីវកម្មនេសាទ និង ការកើនឡើងនៃតំរូវការត្រី និង ផលិតផលវារីសត្វ ការសង្ឃឹមជឿជាក់របស់វារីវប្បកម្ម ដើម្បីបង្កើនការរួមចំណែករបស់វាទៅក្នុងផលិតកម្មម្ហូបអាហារវារីសត្វពិភពលោកយ៉ាងខ្ពស់ ហើយសង្ឃឹមថាវារីវប្បកម្មនឹងបន្តពង្រឹងតួនាទី ដើម្បីចូលរួមចំណែកក្នុងសុវត្ថិភាពស្បៀង និង ការកាត់បន្ថយភាពក្រីក្រនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ។ ប៉ុន្តែត្រូវបានកត់សំគាល់ថា វារីវប្បកម្មមានវិសាលភាពខុសគ្នាយ៉ាងទូលំទូលាយក្នុងការងារប្រតិបត្តិជាក់ស្តែង ដោយផ្តោតទៅលើពូជ (រាប់បញ្ចូលទាំងសារាយសមុទ្រ សិប្បីសត្វ ពពួកសត្វគតឆ្អឹងកង ត្រី និង ពពួកវារីសត្វផ្សេងទៀត) បរិស្ថាន និង ប្រព័ន្ធដែលបានប្រើប្រាស់ជាមួយនឹងការប្រើប្រាស់ប្រភពធនធានផ្សេងៗគ្នាឱ្យបានចូលរួមជាតំរូ ផ្តល់ការជ្រើសរើសយ៉ាងទូលំទូលាយដើម្បីឱ្យមានផ្លូវច្រើនសំរាប់ជំរុញផលិតកម្មម្ហូបអាហារ និង បង្កើនចំណូលក្នុងទីជនបទ និង តំបន់ជាយក្រុង ។

ក្នុងទស្សនៈផលប្រយោជន៍នៃម្ហូបអាហារ សង្គម សេដ្ឋកិច្ច និង បរិស្ថានជាចំបងដែលជាទូទៅអាចបញ្ចូលជាមួយការងារប្រតិបត្តិវារីវប្បកម្មកន្លងមក ហើយសេចក្តីសង្ឃឹមដ៏ល្អសំរាប់ឈានទៅរកការអភិវឌ្ឍ និង ពង្រីកវិស័យ ។ វាមានសារៈសំខាន់ណាស់សំរាប់កិច្ចខិតខំប្រឹងប្រែងតំរង់ទៅរកការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព និង សក្តានុពលសង្គម ហើយបញ្ហាបរិស្ថាននានាត្រូវបានកាត់បន្ថយ ។ វារីវប្បកម្មក៏ដូចប្រព័ន្ធចិញ្ចឹមសត្វទៅលើគោកដែរគឺត្រូវប្រឈមមុខនឹងបញ្ហាមួយចំនួនរួមមានបង្កើនការប្រឡងប្រណាំង ដើម្បីលីមីតប្រភពដូចជាៈ ទឹក ដីនិងចំណីផ្តត់ផ្គង់ឱនភាពនៃប្រភពបរិស្ថានដែលបានប្រើប្រាស់ ឬ ចាំបាច់ ខ្វះការទទួលស្គាល់ស្របច្បាប់ អ្នកប្រើប្រាស់ធនធានខ្វះការគាំទ្រពីសំណាក់ស្ថាប័ន និង ច្បាប់ ការធ្វើឱ្យហួសពីលក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយបច្ចុប្បន្នធ្វើឱ្យខូចប្រយោជន៍សាធារណៈដែលជាលទ្ធផលបណ្តាលមកពីករណីមួយចំនួនពាក់ព័ន្ធទៅនឹងឱនភាពរបស់បរិស្ថាន និង បង្អាក់ការងារសង្គមកិច្ចបានបណ្តាលមកពីការប្រតិបត្តិវារីវប្បកម្មបែបផ្សេងគ្នា ។

លើសលើទស្សនៈសេដ្ឋកិច្ច ការលំបាកចំបងចំពោះមុខនឹងត្រូវថយចុះ ទៅពេលដែលជំរុញការងារអភិវឌ្ឍវារីវប្បកម្ម។ លក្ខណៈវិនិច្ឆ័យខាងក្រៅធំពីរនឹងត្រូវបានយកចិត្តទុកដាក់ ។ ទីមួយគឺលក្ខណៈវិនិច្ឆ័យទាំងអស់បង្កឡើងដោយសកម្មភាពផ្សេងៗ បានបង្កើតលក្ខខណ្ឌមិនសមរម្យរវាងគ្នាដូចជា បណ្តាំទំរង់នៃប្រជាពលរដ្ឋ ឬ កត្តាជះឥទ្ធិពលដែលបណ្តាលមកពីសកម្មភាពមនុស្ស ហើយដែលមិនអាចយកមកទូទាត់គ្នាបាន ឬ បង់ប្រាក់ប្រកបដោយភាពទទួលខុសត្រូវសំរាប់ការជះឥទ្ធិពលមកពីខាងក្រៅ។ ទីពីរលក្ខណៈគឺវិនិច្ឆ័យទាំងអស់បង្កឡើងដោយការប្រលងប្រណាំងចូលទៅក្នុងដែននៃសាធដើម្បីបានចែកលំកែលធនធាន ( ឧទាហរណ៍ ទឹក ឬ ផ្ទៃកណាមួយនៃតំបន់ឆ្នេរ) ហើយដែលធ្វើឱ្យគ្មានប្រសិទ្ធភាពសេដ្ឋកិច្ចដូចជាវិនិយោគទុន និង កំលាំងពលកម្មច្រើនតែទទួលបានប្រាក់ចំណេញតិចតួច ។ គួរតែប្រយ័ត្នប្រយែងយកចិត្តទុកដាក់បន្ថយកត្តាខាងក្រៅ ដើម្បីកំណត់គំរិតដែលអាចទទួលយកបានលទ្ធផលនៃការជះឥទ្ធិពលអវិជ្ជមាន ឬ ខ្វះខ្វាយសេដ្ឋកិច្ចបណ្តាលមកពីសកម្មភាពវារីវប្បកម្ម ដូចជាលទ្ធផលដែលបានមកពីការធ្វើសេចក្តីសំរេចចិត្ត ឬ សកម្មភាពនៃភ្នាក់ងារសេដ្ឋកិច្ចលើសកម្មភាពវារីវប្បកម្ម ។

នៅពេលដែលក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផលចែងច្បាស់ពីសកម្មភាពនានាដែលបានទទួលយកដោយបណ្តាប្រទេស វាជាមធ្យោបាយដៅទៅលើក្រុមមនុស្ស ឬស្ថាប័នដែលទទួលប្រយោជន៍ ឯកជនឬសាធារណៈដែលបានរួមចំណែកឬពាក់ព័ន្ធជាមួយវារីវប្បកម្ម។ អ្នកជំនាញគ្រប់គ្រងនឹងបានបង្កើននូវតួនាទីគន្លឹះសំរាប់ដើរតួក្នុងការជំរុញប្រសិទ្ធិភាពកិច្ចសហការជាមួយនឹងចំណោមអ្នកដើរតួផ្សេងៗទៀតដើម្បីជំរុញការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ។ ការទទួលខុសត្រូវដើម្បីអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ចាំបាច់ត្រូវចែករំលែកអំណាចទាំងអស់ទៅឱ្យវារីវប្បករ ផលិតករ និង អ្នកផ្គត់ផ្គង់ផលិតផលវារីវប្បកម្ម អ្នកកែច្នៃ និង ពាណិជ្ជករនៃផលិតផលវារីវប្បកម្ម ស្ថាប័នហិរញ្ញវត្ថុ អ្នកស្រាវជ្រាវ ក្រុមដែលមានផលប្រយោជន៍ ជាពិសេសសមាគមឯកទេស អង្គការមិនមែនរដ្ឋាភិបាល និង ស្ថាប័នផ្សេងៗទៀត ។

ភារកិច្ចសំខាន់គឺបង្កើតសេចក្តីប្តេជ្ញាចិត្តដើម្បីកសាងការសន្ទនានិងបង្កើនប្រសិទ្ធិភាពសហការចំណោមដៃគូរក្នុងការអភិវឌ្ឍវារីវប្បកម្មនៅថ្នាក់មូលដ្ឋាន ជាតិ និង អន្តរជាតិ។ កិច្ចសហការដើម្បីអភិវឌ្ឍន៍វារីវប្បកម្មប្រកបដោយនិរន្តរភាព ចាំបាច់ត្រូវទទួលស្គាល់នូវភាពផ្សេងគ្នានៃការប្រតិបត្តិវារីវប្បកម្ម ក៏ដូចជាខុសគ្នាខាងនយោបាយ លក្ខខណ្ឌសេដ្ឋកិច្ច និង សង្គមដែលគេបាន និង កំពុងជួបប្រទះ ។ សមត្ថភាពនៃការអភិវឌ្ឍប្រទេសជាតិដើម្បីអនុវត្តអនុសាសន៍របស់ក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផលគួរតែយកមកគិតពិចារណាឱ្យបានត្រឹមត្រូវ( មើលមាត្រា ៥ នៃក្រមប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល គ្រង់កថាខ័ណ្ឌតំរូវការពិសេសនៃបណ្តាប្រទេសកំពុងអភិវឌ្ឍ) ។ វាជាការសំខាន់ណាស់ដែលកាលៈទេសៈនិងលក្ខខណ្ឌនានាក្នុងប្រទេសកំពុងអភិវឌ្ឍត្រូវបានកត់សំគាល់យ៉ាងពេញទំហឹងក្នុងលក្ខខណ្ឌនៃតំរូវការរបស់គេសំរាប់ជួយហិរញ្ញវត្ថុ និង បច្ចេកទេស ការផ្ទេរបច្ចេកវិទ្យា បណ្តុះបណ្តាល និង កិច្ចសហការវិទ្យាសាស្ត្រសំរាប់បង្កើនសមត្ថភាព ដើម្បីអនុវត្តវារីវប្បកម្មជាក់លាក់តាមអនុសាសន៍របស់ក្រមប្រតិបត្តិ ។

ឯកសារបច្ចុប្បន្នមិនអាច និង មិនបានត្រៀមបំរុងសំរាប់ឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែង និង បញ្ហាមួយចំនួនដែលជួបប្រទះនឹងចរន្តអភិវឌ្ឍវារីវប្បកម្ម និរន្តរភាព សេចក្តីត្រូវការ និង មធ្យោបាយដើម្បីជំរុញសកម្មភាពសហការ និង ទទួលខុសត្រូវសកម្មភាពទាំងអស់ដែលបានចូលរួម

បានទេ ។ ដោយសារតែការអនុវត្តវារីវប្បកម្មប្រភេទផ្សេងៗគ្នាជុំវិញពិភពលោក វាគ្រាន់តែផ្តល់ការពន្យល់ពីគោលការណ៍នៃមាត្រា ៩ (ការអភិវឌ្ឍវារីវប្បកម្ម) នៃក្រមប្រតិបត្តិដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល ។ ការបកស្រាយពន្យល់ទាំងនេះប្រើប្រាស់សំរាប់ជាសេចក្តីណែនាំទូទៅ ហើយអាចចាត់ទុកជាសំណើ ឬ ការអង្កេតបំរុងទុក ដើម្បីជួយជាប្រយោជន៍ក្នុងការសំគាល់លក្ខណៈវិនិច្ឆ័យ ហើយជ្រើសរើសសំរាប់សកម្មភាពរបស់គេដែលជាដៃគូរសហការក្នុងការគាំទ្រការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ជួនកាលភាពចាំបាច់នៃការកត់សំគាល់ និង ការយល់ដឹងផ្សេងគ្នាអាចចូលរួមចំណែកទៅក្នុងការអភិវឌ្ឍ និង ផលិតកម្មវារីវប្បកម្មប្រកបដោយនិរន្តរភាព ។

សេចក្តីណែនាំលំអិតពីបញ្ហាជាក់ស្តែង និង ប្រធានបទគ្របដណ្តប់ដោយមាត្រា ៩ នៃក្រមប្រតិបត្តិកំពុងរៀបចំ ឬ នឹងរៀបចំឡើងនៅពេលអនាគតដោយនាយកដ្ឋានជលផលរបស់ FAO ក្នុងកិច្ចសហការជាមួយដៃគូរដែលចាប់អារម្មណ៍ ។ ប្រហែលជាចាំបាច់ត្រូវផ្តល់ការណែនាំជាក់ស្តែងស្តីពីប្រភេទប្រព័ន្ធវារីវប្បកម្មណាមួយពីក្រុមពូជដែលបានជ្រើសរើស ឬ របស់ប្រើប្រាស់ផ្សេងៗ ឬ ការខិតខំអភិវឌ្ឍវារីវប្បកម្មក្នុងបរិស្ថាន ឬ តំបន់ដែលបានកំណត់ ។ គួរកត់សំគាល់ថាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ FAO មានមូលដ្ឋាន ប្រទេស តំបន់ និង អន្តរជាតិជាច្រើនបាន និង កំពុងផ្តួចផ្តើមជំរុញការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ។ FAO កំពុងជំរុញកិច្ចសហការនេះដូចជា ធ្វើទំនាក់ទំនងដើម្បីអនុវត្តបណ្តាគោលការណ៍នៃក្រមប្រតិបត្តិ ។ សង្ឃឹមថាកិច្ចសហការក្នុងការរៀបចំ និង ការអនុវត្តសេចក្តីណែនាំជាក់ស្តែង ដើម្បីនិរន្តរភាពវារីវប្បកម្ម និង ការអនុវត្តប្រកបដោយភាពទទួលខុសត្រូវ និង រួមចំណែកក្នុងការកត់សំគាល់កាន់តែខ្លាំងឡើងនៃវារីវប្បកម្ម ជាពិសេសក្នុងលក្ខខណ្ឌនៃប្រយោជន៍របស់វា និង ភាពខុសគ្នានៃការអនុវត្ត និង ការចូលរួមរបស់ប្រជាពលរដ្ឋ ។ គួរកត់សំគាល់ថាសេចក្តីណែនាំដទៃទៀតនៅក្នុងមាត្រានានារបស់ក្រមប្រតិបត្តិ រាប់បញ្ចូលទាំងបញ្ហាទាំងឡាយស្តីពី "ការធ្វើសមាហរណកម្មវិស័យជលផលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ"[១] "ការគ្រប់គ្រងជលផល"[២] និង ការប្រុងប្រយ័ត្នដែលជាប់ទាក់ទងទៅនឹងការនេសាទត្រី និង ការបញ្ចូលពូជត្រី

[១] ការធ្វើសមាហរណកម្មវិស័យជលផលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ។ សេចក្តីណែនាំបច្ចេកទេសដើម្បីក្រមប្រតិបត្តិទទួលខុសត្រូវវិស័យជលផលរបស់ FAO លេខ៣ រ៉ូម FAO ១៩៩៦ ១៧ទំព័រ ។

[២] ការគ្រប់គ្រងជលផល ។ សេចក្តីណែនាំបច្ចេកទេសដើម្បីក្រមប្រតិបត្តិទទួលខុសត្រូវវិស័យជលផលរបស់ FAO លេខ៤ រ៉ូម FAO ១៩៩៧ ៨២ ទំព័រ ។

ថ្មី "[៣] ដែលមានទិដ្ឋភាពកំពុងគ្របដណ្តប់ទាក់ទងទៅនឹងវារីវប្បកម្ម រាប់បញ្ចូលវារីវប្បកម្មផ្អែកលើជលផល ។ បន្ថែមពីលើនេះឯកសារណែនាំផ្សេងៗទៀតដែលពាក់ព័ន្ធបាន និង កំពុងរៀបចំបង្កើយរួមមាន:

-ការណែនាំបច្ចេកទេសដាច់ដោយឡែក និង វិញ្ញាបនបត្រសុខភាព ដើម្បីភាពទទួលខុសត្រូវការផ្លាស់ប្តូរទីកន្លែងនៃបណ្តាសត្វរាងវារីសត្វ និង វារីរុក្ខជាតិ ។

- សេចក្តីណែនាំបច្ចេកទេស ដើម្បីការអនុវត្តធ្វើចំណីអាហារវារីសត្វឱ្យបានល្អ ។

- រចនាសម្ព័ន្ធសំរាប់ការប្រើប្រាស់ប្រកបដោយភាពទទួលខុសត្រូវនៃពូជបញ្ចូលថ្មី ។

-ក្រមប្រតិបត្តិនៃការអនុវត្តភូតតាមអនាម័យសំរាប់ផលិតផលវារីវប្បកម្ម( បានរៀបចំនៅខាងក្នុងរចនាសម្ព័ន្ធនៃ FAO/WHO គណៈកម្មាធិការស្បៀងអាហារ Codex ។

- សេចក្តីណែនាំដើម្បីការអភិវឌ្ឍ និង ការគ្រប់គ្រងជលផលទឹកសាប ។

- សេចក្តីណែនាំ និង លក្ខណៈវិនិច្ឆ័យដើម្បីជំរុញឱ្យកាន់តែប្រសើរឡើងនូវវិសាលភាពនៃភាពទទួលខុសត្រូវសំរាប់វារីវប្បកម្មផ្អែកលើជលផល ។

-ក្បួនតម្រា និង សេចក្តីណែនាំបច្ចេកទេសដើម្បីការកសាងឡើងវិញហេដ្ឋារចនាសម្ព័ន្ធទន្លេ និង ធ្វើឱ្យប្រសើរឡើងនៃទីជំរកត្រី ។

-សេចក្តីណែនាំស្តីពីការធ្វើសមាហរណកម្មកសិកម្ម រុក្ខាប្រមាញ់ និង នេសាទទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ។

### ១.២. រចនាសម្ព័ន្ធ និង មាតិកានៃឯកសារនេះ

ឯកសារនេះរៀបចំឡើងទៅតាមរចនាសម្ព័ន្ធនៃមាត្រា៩ *ការអភិវឌ្ឍវារីវប្បកម្ម* នៃក្រមប្រតិបត្តិដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យជលផល (ពីពេលនេះតទៅហៅថា "ក្រមប្រតិបត្តិ ")។ គោលការណ៍នីមួយៗបានពិពណ៌នាច្បាស់លាស់ដើម្បីផ្តល់ដល់អ្នកអានជាមួយនឹងការពន្យល់ពាក់ព័ន្ធដែលមានសំណួមពរ និង ការអង្កេតនានា ។ មាត្រា ៩ មាន ៤ ផ្នែកដូចដែលបាន

---

[៣] ការប្រើប្រាស់ពូជដែលជាប់ទាក់ទងទៅនឹងការធ្វើនេសាទ និង ការពង្រួមពូជត្រី ( FAO Fish. Tech. Pap., 3001 ) សេចក្តីណែនាំបច្ចេកទេសដើម្បីភាពទទួលខុសត្រូវក្នុងវិស័យជលផលរបស់ FAO លេខ២ រ៉ូម FAO ១៩៩៦ ៨៤ទំព័រ ។

អភិវឌ្ឍក្នុងពេលរៀបចំក្រមប្រតិបត្តិ ។ ផ្នែកទី១ យកចិត្តទុកដាក់ជាចំបង ពិពណ៌នាពីបញ្ហាក្នុងតំបន់ ដែលស្ថិតក្រោមយុត្តាធិការជាតិ ។ ផ្នែកទី២ វែកញែកពាក់ព័ន្ធទៅនឹងចំណុចនានាជាបុព្វសិទ្ធត្រួតត្រា របស់ប្រទេសដែលអាចជះឥទ្ធិពលទៅលើប្រទេសផ្សេងៗ ។ ផ្នែកទី៣ គ្របលើបញ្ហាពាក់ព័ន្ធទៅ នឹងការប្រើប្រាស់ប្រភពសេនេទិច ។ ផ្នែកបញ្ចប់ យកចិត្តទុកដាក់ទៅលើសំណួរនានានៅក្នុង កិរិតផលិតកម្មដែលពាក់ព័ន្ធនឹងផ្នែកនេះ ។

បណ្តាគោលការណ៍ដែលបានទទួលយកដោយមាត្រា ៩ នៃក្រមប្រតិបត្តិត្រូវបានរំលេច ដោយអក្សរឆ្នាក់។ ការពិពណ៌នាគាំទ្របន្ថែមសរសេរក្នុងស៊ុមបួនជ្រុងហើយត្រូវបានជ្រើសរើសជា បង្អែកដែលអាចប្រើប្រាស់ក្នុងការពិភាក្សា និង តាមដានការងារបន្ត ។ ឯកសារបង្អែកដែលបានផ្តល់ ជាលេខរៀងក្នុងអត្ថបទទាំងមូល ហើយអាចរកឃើញនៅខាងផ្នែកចុងនៃឯកសារនេះ។ អ្នកអានទាំង អស់ត្រូវបានលើកទឹកចិត្ត ដើម្បីផ្លាស់ប្តូរយោបល់ជាមួយនឹងអ្នកផ្សេងទៀតដែលចាប់អារម្មណ៍នឹង ឯកសារបច្ចេកទេស ឯកសារណែនាំ និង ព័ត៌មានស្តីពីបទពិសោធន៍ដែលអាចចូលរួមចំណែកក្នុងការ ប្រតិបត្តិសកម្មភាពនានាដែលបានតំរូវ។ អ្នកអានក៏បានអញ្ជើញឱ្យចូលរួមផ្ញើព័ត៌មានទៅនាយកដ្ឋាន ជលផលរបស់ FAO និង ដោយមូលហេតុចូលរួមចំណែកដើម្បីអភិវឌ្ឍកែលំអឱ្យបានកាន់តែប្រសើរ ឡើង និងធ្វើឱ្យទាន់សម័យនូវសេចក្តីណែនាំនានាដែលបានរៀបចំក្នុងការគាំទ្រការអភិវឌ្ឍវារីវប្បកម្ម ប្រកបដោយនិរន្តរភាព ។

### ១.៣. ការប្រើប្រាស់ពាក្យបច្ចេកទេស

<u>វារីវប្បកម្ម</u>:

វារីវប្បកម្មបានកំណត់នៅទីនេះដោយផ្អែកតាមនិយមន័យដែលកំពុង និង បានប្រើប្រាស់ ដោយ FAO ដើម្បីគោលបំណងស្ថិតិ "វារីវប្បកម្មជាការចិញ្ចឹមសារពាង្គកាយវារីសត្វ និង រុក្ខជាតិ រាប់បញ្ចូលទាំងត្រី សិប្បីសត្វ ពពួកក្រំ ខ្ចៅ ខ្យង...។ល។ និង វារីរុក្ខជាតិគ្រប់ប្រភេទ ។ ការធ្វើវារីវប្បកម្មមានន័យសង្ខេបខ្លីគឺអន្តរាគមន៍ក្នុងដំណើរការផ្សេងៗដើម្បីជំរុញផលិតកម្ម ដូចជា សន្និធិធម្មតា ចំណី ការទប់ស្កាត់សត្វដែលស៊ីសាច់សត្វដទៃជាអាហារ...។ល។ ការធ្វើវារីវប្បកម្មក៏ មានន័យថាឯកជន ឬ សមូហភាពជាម្ចាស់នៃសន្និធិដែលបានប្រមូលផល ហើយដើម្បីគោលបំណង

ស្ថិតិ សីវភាគ្គវារីសត្វ និង វារីរុក្ខជាតិដែលបានប្រមូលផលដោយបុគ្គលម្នាក់ៗ ឬ សមូហភាពជាម្ចាស់របស់វា តាមរយៈការរួមចំណែកទៅក្នុងវារីវប្បកម្ម នៅពេលដែលវារីសីវភាគ្គបានធ្វើអាជីវកម្មជាសាធារណៈ ដូចជាទ្រព្យសម្បត្តិសាធារណៈដែលភ្ជាប់ជាមួយ ឬ គ្មានអាជ្ញាប័ណ្ណសមស្រប គឺជាការធ្វើអាជីវកម្មជលផល ។

វារីវប្បកម្មអាស្រ័យជលផលៈ

អត្ថបទក៏មានបញ្ចូលកថាខណ្ឌមួយចំនួនសំរាប់វារីវប្បកម្មអាស្រ័យជលផលបានទទួលយកដើម្បីជាមធ្យោបាយធ្វើអាជីវកម្មដែលបានថែទាំដោយសន្និធិជាមួយនឹងវត្ថុធាតុដើមបានលើកឡើងនៅក្នុងក្របខណ្ឌបង្កើតវារីវប្បកម្ម ។ ប៉ុន្តែនិយមន័យនេះចង្អៀតពេកដើម្បីគ្របដណ្តប់ទៅលើតំលាតនៃការងារប្រតិបត្តិ គ្រប់គ្រងដែលបានដឹងដូចជាការជំរុញហើយសំរាប់គោលបំណងនៃឯកសារនេះ ។

និយមន័យ[៤] សំរាប់វារីវប្បកម្មអាស្រ័យជលផលនេសាទគឺជាៈ

- សកម្មភាពនានាសំដៅបំពេញបន្ថែម ឬ គាំទ្រការជ្រើសរើសប្រភេទវារីសត្វមួយ ឬ ច្រើន និងបង្កើនផលិតផលសរុប ឬ សមាសភាពនៃផលិតផលត្រីដែលបានជ្រើសរើសនៅក្រោយក៏រិតដែលជាដំណើរវិវឌ្ឍន៍នៃធនធានតាមរយៈនិរន្តរភាព ។ ក្នុងន័យនេះ វារីវប្បកម្មអាស្រ័យជលផល រួមមានវិធានការជំរុញដែលអាចចាត់ទុកជាទំរង់នៃការណែនាំនូវប្រភេទពូជថ្មី សន្និធិធម្មជាតិ និង ដែនទឹកសិប្បនិមិត្ត ការប្រើប្រាស់ជី គ្រឿងយន្តបរិស្ថាន រាប់បញ្ចូលទាំងការកែលំអមីជរក និង ការកែប្រែដែនទឹក រាប់បញ្ចូលទាំងការលុបបំបាត់នូវប្រភេទពូជដែលមិនពេញចិត្ត ឬ សមាសភាព ប្រភេទដែលបានជ្រើសរើសកែលំអសេនេទិចនៃប្រភេទពូជនានាដែលបានបញ្ចូលថ្មី ។

សុវត្ថិភាពស្បៀងៈ

សុវត្ថិភាពស្បៀងកើតឡើងនៅពេលដែលប្រជាពលរដ្ឋគ្រប់រូបមានកាយវប្បកម្ម និង សេដ្ឋកិច្ចល្មមគ្រប់គ្រាន់ សុវត្ថិភាព និង អាហារូបត្ថម្ភឆ្លើយតបទៅនឹងតំរូវការសារធាតុចិញ្ចឹម និង ចំណីអាហារចូលចិត្តសំរាប់ធ្វើសកម្មភាព និង សុខភាពក្នុងជីវិតគ្រប់ពេលវេលា(ឯកសារបង្អែក១) ។

---

[៤] និយមន័យសំរាប់វារីវប្បកម្ម [illegible] FAO [illegible] ១៩៩៧ ក្នុង Dhaka បង់ក្លាដែស ។

ការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាព:

ការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាពគឺជាការគ្រប់គ្រង និង អភិរក្សធនធានធម្មជាតិជាមូលដ្ឋាន ហើយផ្តោតទៅលើការប្រែប្រួលនៃបច្ចេកទេស និង ស្ថាប័នដូចជា: ឥរិយាបថដើម្បីបាននូវសមិទ្ធិផល និង បន្តបំពេញតំរូវការមនុស្សជំនាន់បច្ចុប្បន្ន និង អនាគត ។ ការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាពក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ) សំចៃដី ទឹក ដើមឈើ និង ប្រភពសេនេទិចសត្វគឺមិនធ្វើឱ្យមានឱនភាពខាងបរិស្ថាន បច្ចេកទេស សេដ្ឋកិច្ចសមស្របដែលអាចសំរេចបាន និង អាចទទួលស្គាល់ពីសង្គម ( ឯកសារបង្អែក២) ។

**២. ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវរាប់បញ្ចូលទាំងវារីវប្បកម្មផ្អែកលើជលផលក្នុងតំបន់ដែលស្ថិតក្រោមយុត្តាធិការជាតិ**

( ក្រមប្រតិបត្តិ មាត្រា ៩.១ )

**" បណ្តាប្រទេសគួរតែបង្កើត ថែរក្សា និង រៀបចំរចនាសម្ព័ន្ធរដ្ឋបាលដែលជួយសម្របសម្រួលការអភិវឌ្ឍវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវ " ។**

**( ក្រមប្រតិបត្តិ មាត្រា ៩.១.១)**

ការទទួលខុសត្រូវទូទៅ: ដើម្បីជំរុញ គាំទ្រ និង ធ្វើឱ្យមានប្រសិទ្ធិភាព និង ភាពទទួលខុសត្រូវវិស័យវារីវប្បកម្ម ប្រទេសទាំងអស់គួរតែបង្កើត ថែរក្សា និង រៀបចំជាស្រេចនូវរចនាសម្ព័ន្ធរដ្ឋបាល និង ច្បាប់ឱ្យបានសមស្រប ដើម្បីបញ្ជាក់ថាការប្រតិបត្តិវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវបានផ្សព្វផ្សាយ និង អនុវត្តស្របនឹងយុត្តាធិការជាតិ ។

ប្រអប់ ១. អំណាចរដ្ឋាភិបាលទទួលខុសត្រូវចំពោះការអភិវឌ្ឍវារីវប្បកម្មដែលមានស្រាប់ និង សំរាប់អនាគត ហើយប្រទេសជាច្រើននឹងបន្តតួនាទីសំខាន់ក្នុងការជំរុញ និង កែតំរូវការអភិវឌ្ឍវារីវប្បកម្ម ។ ក្នុងប្រទេសមួយចំនួន ឧទាហរណ៍ រដ្ឋបាលដែលមានស្រាប់ និង រចនាសម្ព័ន្ធច្បាប់ចាំបាច់ត្រូវកែសំរួលដើម្បីឆ្លើយតបទៅនឹងលក្ខណៈជាក់ស្តែង និង តំរូវការរបស់វិស័យ ។ ការអនុញ្ញាត ច្បាប់ និង វិធានការច្បាប់ចាំបាច់ត្រូវតែបែងចែកសិទ្ធិទៅតាមកំរិតថ្នាក់ឱ្យបានច្បាស់លាស់ និង ការទទួលខុសត្រូវរបស់វារីវប្បករ ។ តាមធម្មតា វារីវប្បកម្មគឺស្ថិតនៅក្រោមនីតិកម្មជលផលទូទៅ

ជាមូលដ្ឋានទៅឡើយ ហើយវាជានិច្ចកាលមិនបានកត់សំគាល់សមភាពរវាងវារីវប្បកម្ម និង កសិកម្មទេ។ វាមានទំហំធំធេងណាស់សំរាប់ពង្រីកការយកចិត្តទុកដាក់ទៅលើគ្រឹះស្ថានសាធារណៈ ទាំងពីរ និង សាធារណៈទូទៅអំពីវារីវប្បកម្ម និង ភាពស្រដៀងគ្នានឹងកសិកម្ម ។ ការងារនេះអាច សំរេចបានតាមរយៈកិច្ចខិតខំសហការគ្នារវាងវារីវប្បករ រដ្ឋអំណាច ប្រព័ន្ធព័ត៌មាន និង ការផ្តួចផ្តើម គំនិតអង្គការមិនមែនរដ្ឋាភិបាល ។ ការធ្វើបែបនេះអាចចូលរួមចំណែកដើម្បីអភិវឌ្ឍច្បាប់ និង បទ បញ្ញាផ្សេង១ដែលឆ្លុះបញ្ចាំងពីការយល់ដឹង និង ការកត់សំគាល់ចរិត និង ភាពចាំបាច់នៃវារីវប្បកម្ម ។

<u>ការរៀបចំចាត់តាំងអាជ្ញាធរៈ</u>

ប្រទេសទាំងអស់គួរតែចាត់តាំង ឬ បង្កើតអាជ្ញាធរមួយ ឬ អាជ្ញាធរដែលមានសមត្ថភាព ឱ្យអំណាច និង សមត្ថភាពដើម្បីជំរុញប្រកបដោយប្រសិទ្ធិភាព គាំទ្រ និង កែតំរូវវារីវប្បកម្ម និង វារីវប្បកម្មអាស្រ័យផលផល ។ ទំនាក់ទំនងសមស្របរវាងស្ថាប័ន និង រដ្ឋអំណាចនានាដែលពាក់ព័ន្ធ នឹងកសិកម្ម អភិវឌ្ឍជនបទ ធនធានទឹក បរិស្ថាន សុខាភិបាល អប់រំបណ្តុះបណ្តាល និង ស្ថាប័ន ផ្សេង១ទៀតក៏គួរតែបង្កើតឡើងដែរ ។ ការពាក់ព័ន្ធទាំងនេះគួរតែមានភាពជាក់លាក់នៅក្នុង រចនាសម្ព័ន្ធនីតិប្បញ្ញត្តិ ។

<u>រចនាសម្ព័ន្ធច្បាប់ៈ</u>

ប្រទេសទាំងអស់ និង អាជ្ញាធរវារីវប្បកម្មនានា គួរតែធានាថាវិស័យវារីវប្បកម្មមានការ អនុញ្ញាតត្រឹមត្រូវ និង ការពារដោយឧបករណ៍ច្បាប់ដូចជាៈ ច្បាប់ បទបញ្ជា បញ្ជា កិច្ចព្រមព្រាង លិខិតបទដ្ឋានផ្សេង១...។ល។ ដែលកំណត់រួចហើយនូវការទទួលខុសត្រូវសិទ្ធិអំណាចរបស់វារីវប្បករ ក្នុងរបៀបមួយដែលស្របទៅតាមចរន្ត សក្តានុពលប្រតិបត្តិវារីវប្បកម្ម និង ការអនុវត្តទាំងឡាយ ដើម្បីអាចឱ្យប្រៀបធៀបសកម្មភាព (ឯកសារបង្អែក ៣.៤) ។

<u>ការយល់ដឹង និង ជំរុញឱ្យអនុវត្តច្បាប់វារីវប្បកម្មៈ</u>

បណ្តាប្រទេស និង អាជ្ញាធរវារីវប្បកម្ម គួរតែធានាឱ្យបានច្បាស់ថារាល់ឧបករណ៍ច្បាប់ អាចអនុវត្តបានរួមមានៈ ច្បាប់ បទបញ្ជា បញ្ជា កិច្ចព្រមព្រាង លិខិតបទដ្ឋានផ្សេង១ ...។ល។ បានចាប់ផ្តើមឡើងក្នុងទ្រង់ទ្រាយដូចដែលធ្លាប់យល់រួចមកហើយ ដោយសកម្មភាពនានារបស់វិស័យ

វារីវប្បកម្មដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រស្រ័យទាក់ទងទៅគេ ហើយនៅចុងបញ្ចប់ឧបករណ៍ច្បាប់ទាំងអស់អាចបង្ខំឱ្យអនុវត្តតាម និង បានអនុវត្តតាម ( ឯកសារបង្អែក ៥.៦.៧ ) ។

ប្រអប់២.

ក្រមប្រតិបត្តិ( ច្បាប់ទន់ ) ជានិច្ចកាលសមស្របបំផុតទៅនឹងគោលបំណងដើម្បីធ្វើឱ្យត្រឹមត្រូវនូវការងារប្រតិបត្តិវារីវប្បកម្ម ហើយមានតួនាទីយ៉ាងសំខាន់ក្នុងការដើរតួជា " ឧបករណ៍កែតំរូវ " ។នៅពេលដែលសំរេចចិត្តរួមគ្នារវាងច្បាប់ទន់ និង ច្បាប់រឹង វាមានប្រយោជន៍សំរាប់យកមកពិនិត្យទៅលើសារជាតិ គោលបំណងជាមូលដ្ឋាននៃវិធានដែលបានអនុវត្តសកម្មភាពវារីវប្បកម្មដូចជា ដើម្បី កំណត់ឱ្យបានច្បាស់លាស់នូវតំរូវការចាំបាច់កែតំរូវ និង ត្រួតពិនិត្យអនាគតកាល (ដំណើរការសង្គម) របស់វារីវប្បករ ។ ក្នុងករណីជាច្រើនអាចរកឃើញថាមានការចាំបាច់តិចតួចសំរាប់វិធានការទាំងនោះ ប៉ុន្តែវាជាការចាំបាច់ ដើម្បីការពារ និង ជំរុញសកម្មភាពវារីវប្បកម្មដែលមានទ្រង់ទ្រាយជាប្រពៃណីនៃការអនុវត្តច្បាប់ដែលបានចាប់បង្ខំ បញ្ចុះបញ្ចូលឱ្យអនុវត្តន៍វិន័យដោយសហគមន៍ និង ការពិន័យរដ្ឋបាល ជាទូទៅមិនសមទៅនឹងបញ្ហាក្នុងវារីវប្បកម្មទេ ក្នុងបញ្ហាពិសេសខ្លះ ដូចជាគុណភាពផលិតផលដែលស្នើឱ្យជំរុញលើកទឹកចិត្តការចូលរួម និង ការទទួលយកនៃវិធានការណ៍សមស្របប្រសើរជាងការធ្វើឱ្យមានភាពប្លែកគ្នារវាងខុស និង ត្រូវ ( អ្វីដែលស្របច្បាប់ និង មិនស្របច្បាប់) ។ការដែលពោងស្អិតជាប់ទៅនឹងក្រមប្រតិបត្តិអាចមានបញ្ហានៅពេលដែលគេមិនអាចបង្ខំឱ្យប្រតិបត្តិតាម ប៉ុន្តែគេហាក់ដូចជាត្រូវបានអនុវត្តតែចំពោះអ្នកដែលពាក់ព័ន្ធ ហើយដាក់ទំងន់សីលធម៌តែចំពោះអ្នកអនុវត្ត ។ ប៉ុន្តែនៅពេលណាដែលមានការសំរបសំរួលរៀបចំវិធានការច្បាប់ទន់ និង ច្បាប់រឹង ឬដាក់បញ្ចូលគ្នាវាអាចជាភស្តុតាងដ៏មានសារប្រយោជន៍ ដើម្បីធានាទំនាក់ទំនងល្អរវាងអ្នកគ្រប់គ្រងច្បាប់ និង វារីវប្បករ ផ្អែកលើការចូលរួមរបស់វារីវប្បករក្នុងពេលរៀបចំ និង ការទទួលស្គាល់នៃសកម្មភាព និង តំរូវការរបស់គេ ។ ការយកចិត្តទុកដាក់គួរតែត្រូវបានផ្តល់ឱ្យផងដែរដល់សក្តានុពលបញ្ហាដែលអាចជាលទ្ធផលដែលបណ្តាលមកពីការធ្វើឱ្យហួសពីច្បាប់ និង ត្រួតស៊ីគ្នា ឬ ទំនាស់ក្នុងកិច្ចសន្យា ។

"ប្រទេសទាំងអស់គួរតែជំរុញការអភិវឌ្ឍ និង ការគ្រប់គ្រងវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវរាប់បញ្ចូលទាំងការវាយតំលៃជាមុននូវផលប៉ះពាល់ពីការអភិវឌ្ឍវារីវប្បកម្មស្តីអំពីភាពផ្សេងគ្នានៃសេនេទិច និង បូរណភាពប្រព័ន្ធអេកូឡូស៊ីដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រល្អបំផុតដែលមានស្រាប់"។

(ក្រមប្រតិបត្តិ មាត្រា ៩.១.២)

<u>ការទទួលខុសត្រូវទូទៅ:</u>

ប្រទេសនានាគួរតែតាមរយៈអាជ្ញាធរដែលមានសមត្ថភាពរបស់គេ និង ក្នុងភាពជាដៃគូរទាំងអស់ដែលទទួលផលប្រយោជន៍នៃសង្គមស៊ីវិលជំរុញការអភិវឌ្ឍបរិស្ថាន និង បញ្ចូលនិរន្តរភាពវារីវប្បកម្មទៅក្នុងជនបទកសិកម្មនិងការរៀបចំតំបន់ឆ្នេរ លើកតំកើងការយល់ដឹងពីផលប្រយោជន៍សាធារណៈនៃការងារប្រតិបត្តិវារីវប្បកម្មដើម្បីជំរុញផ្គត់ផ្គង់ម្ហូបអាហារ និង ប្រាក់ចំណូលហើយគាំទ្រកិច្ចខិតខំប្រឹងប្រែងសំដៅទៅលើសកម្មភាពដែលប្រកបដោយភាពទទួលខុសត្រូវរបស់វារីវប្បករ អ្នកទាំងឡាយណាដែលពាក់ព័ន្ធ និង អ្នកដែលបានចូលរួមជាមួយវារីវប្បកម្ម (ឯកសារបង្អែក ៨.៩.១០.១១)។

<u>វាយតំលៃជាមុននូវការជះឥទ្ធិពលនៃសេនេទិច:</u>

ឥទ្ធិពលនៃសេនេទិចអាចកើតឡើងពីអន្តរអំពើនៃពូជដែលបានចិញ្ចឹមជាមួយនឹងពូជត្រីធម្មជាតិហើយអាចបណ្តាលមកពីការប្រើប្រាស់ពូជបញ្ចូលថ្មី និង ពូជដែលបានបង្កាត់ ឬ កែលំអសែនដោយកម្មវិធីបង្កាត់ពូជ ឬ បច្ចេកវិទ្យាផ្សេងទៀត។ ឥទ្ធិពលនៃសេនេទិចដែលមិនគួរចង់បានរួមមាន:

-ការធ្វើឱ្យកខ្វក់នៃសែនកំណើតតាមរយៈការបញ្ចូលសែនពូជកាត់ ។

-ឱនភាពនៃពូជកំណើតតាមរយៈដំណើរប្រែប្រួលនៃសែនពីប្រភេទដែល "មិនសមល្មម" ទោះបីដោយសារមធ្យោបាយបង្កាត់ពូជ ឬ ជាការស្មានដោយសារការផ្ទេរសែន។

-បាត់បង់នូវពូជកំណើត ឬ ផ្លាស់ប្តូរក្នុងសមាសភាពពូជតាមរយៈការប្រឡងប្រជែងការស៊ីសាច់ជាអាហារ ឬ ឱនភាពនៃទីជំរក។ ការវាយតំលៃជាមុននូវឥទ្ធិពលនៃសេនេទិចគួរតែរួមបញ្ចូលទាំងការត្រួតពិនិត្យចាំបាច់ស្ថានភាពប្រថុយប្រថាន:

-ប្រូបាប៊ីលីតេនៃការគេចរួចចេញផុតពីប្រព័ន្ធវារីវប្បកម្ម

-ការរស់រានមានជីវិតនៃសរីរាង្គ ប្រសិនបើវាបានគេចចេញរួច

-សមត្ថភាពរបស់សរីរាង្គក្នុងការផលិតឡើងវិញក្នុងទឹកធម្មជាតិដោយខ្លួនឯង និង ជាមួយពូជផ្សេងទៀត

-លទ្ធភាពនៃសែនពិតប្រាកដពីពូជដែលបានផ្ទេរទៅឱ្យពូជក្នុងស្រុក ។

ការវាយតំលៃចាំន់ស្មាននៃសក្តានុពលខូចខាតគួរតែត្រូវបានធ្វើឡើងហើយផ្អែកលើសំណួរគន្លឹះគឺ ៉តើវត្តមាននៃសារពាង្គកាយបង្គ្រោះថ្នាក់ដល់ប្រព័ន្ធអេកូឡូស៊ី ឬ ធ្វើឱ្យប្រសើរឡើងនូវពូជផ្សេង១ក្នុងតំបន់ ៉ទាក់ទងទៅនឹងការលំបាក និង បច្ចេកវិទ្យាសែន ការផ្លាស់ប្តូរបច្ចេកវិទ្យាជះឥទ្ធិពលទៅលើសារពាង្គកាយគួរតែបានវាយតំលៃប្រសើរជាងបច្ចេកវិទ្យាខ្លួនឯង ។ ប្រសិនបើបច្ចេកវិទ្យាអ្វីមួយ ដូចជាការផ្លាស់ប្តូរសែនបានចូលរួមជាមួយកំរិតប្រាកដប្រជាមួយខ្ពស់ដូចដែលឥទ្ធិពលរបស់វាទៅលើសារពាង្គកាយ ឬ បរិស្ថាន បន្ទាប់មកធ្វើតេស្តបទប្បញ្ញត្តិ និង ត្រួតពិនិត្យឱ្យបានម៉ត់ចត់ជាច្រើនទៀតគួរតែបានអនុលោមតាម ។

ប្រអប់ ៣.

ដើម្បីវាយតំលៃជាមុន (ការចាំន់ស្មាននូវផលប៉ះពាល់) សំរាប់ជាមូលដ្ឋាន និង មធ្យោបាយប្រតិបត្តិគួរតែមានបទដ្ឋានបច្ចេកទេសនូវកំរិតនៃការជះឥទ្ធិពលដែលអាចទទួលយកបានជាមុន។ ចំណេះដឹងបច្ចុប្បន្នលើប្រព័ន្ធអេកូឡូស៊ីជាច្រើន និង ភាពខុសគ្នានៃសេនេទិចគឺជានិច្ចកាលមិនគ្រប់គ្រាន់ទេជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងរីកចំរើននិងតំបន់ត្រូពិច ។ ការកំនត់បទដ្ឋានបច្ចេកទេសសំរាប់ឱ្យសែន ៉ ការអភិវឌ្ឍ ៉នៅតែជាការលំបាកដោយសារតែកង្វះខាតនៃព័ត៌មានស្តីពីឥទ្ធិពលនៃវារីវប្បកម្ម/អន្តរអំពើនៃសត្វក្នុងធម្មជាតិការរស់នៅគង់វង្សនៃត្រីចិញ្ចឹមដែលគេចរួចផុត និងកត្តាជះឥទ្ធិពលរបស់វាទៅក្នុងប្រព័ន្ធអេកូឡូស៊ី។ កំរិតដែលអាចទទួលស្គាល់នៃកត្តាជះឥទ្ធិពលវាមិនត្រឹមតែសំខាន់សំរាប់ជាប្រយោជន៍ក្នុងការវាយតំលៃជាមុនប៉ុណ្ណោះទេ តែថែមទាំងចាត់ទុកដូចជាការណែនាំ ឬ ត្រួតពិនិត្យលទ្ធផលនៃការអភិវឌ្ឍវារីវប្បកម្ម ។ របៀបដោះស្រាយដោយប្រុងប្រយ័ត្នជាមុនដើម្បីការគ្រប់គ្រងជលផល (ឯកសារបង្អែក១២) ស្នើឱ្យមានការចាប់ផ្តើមចាំបាច់ ដូចជាផែនការណ៍

បំរុងបន្ទាន់នៅពេលដែលគិតទទួលស្គាល់ថានៅមានចន្លោះប្រហោង ។ កិច្ចសហការរវាងបណ្តាអ្នកវិទ្យាសាស្ត្របរិស្ថាន ជំនាញការវារីវប្បកម្ម និង អ្នករៀបចំផែនការត្រូវការជាចាំបាច់នៅក្នុងករណីជាច្រើន ដើម្បីសំរេចបាននូវរបៀបអនុវត្តដោះស្រាយដោយប្រុងប្រយ័ត្នជាមុន ហើយដើម្បីប្រតិបត្តិនូវរាល់ការវាយតំលៃជាមុន ។ ប៉ុន្តែគួរកត់សំគាល់ថាសូម្បីតែគំរូដែលមានស្រាប់សំរាប់ការប៉ាន់ស្មានវាយតំលៃ និង ការព្យាករណ៍ទុកជាមុននូវឥទ្ធិពលនៃវារីវប្បកម្មបង្កមហន្តរាយទៅលើអេកូឡូស៊ីដែលជារឿយៗស្មុគ្រស្មាញណាស់ ជានិច្ចកាលគឺមានទំហំធំធេងជាក់លាក់ ហើយក្នុងករណីជាច្រើនអាចអនុវត្តបានតែក្នុងតំបន់ក្តៅប៉ុណ្ណោះ ។ ដូច្នេះប្រសិទ្ធិភាពតំលៃ និង បណ្តាវិធីសាស្ត្រវាយតំលៃប៉ាន់ស្មានបន្ទាន់ចាំបាច់ដែលអាចអនុវត្តយ៉ាងងាយស្រួលក្នុងបរិស្ថានត្រូពិច និង ប្រទេសកំពុងអភិវឌ្ឍ ។ ជាទូទៅ អ្នកវិទ្យាសាស្ត្របរិស្ថានអាចជួយឱ្យយើងដឹងនូវភាពខុសគ្នារវាងការពិត និង សម្មតិកម្មគ្រោះថ្នាក់បរិស្ថានដែលជាលទ្ធផលនៃការប្រតិបត្តិវារីវប្បកម្ម ។

"ប្រទេសទាំងអស់គួរតែផលិត និង កែលំអឱ្យបានប្រសើរឡើងជាប្រចាំនូវផែនការ និង យុទ្ធសាស្ត្រអភិវឌ្ឍវារីវប្បកម្មដូចបានស្នើសុំ ដើម្បីធានាថាការអភិវឌ្ឍវារីវប្បកម្មគឺជានិរន្តរភាពអេកូឡូស៊ី និង ដើម្បីអនុញ្ញាតឱ្យបានសមហេតុក្នុងការបែងចែក ប្រើប្រាស់ធនធានដោយវារីវប្បកម្ម និង សកម្មភាពផ្សេងៗទៀត" ។

( ក្រមប្រតិបត្តិ មាត្រា ៩.១.៣ )

<u>ការអភិវឌ្ឍ និង ផែនការគាំទ្រវារីវប្បកម្ម:</u>

នៅក្នុងប្រទេសជាច្រើនមានតំរូវការចាំបាច់បន្តសំរាប់អាជ្ញាធរវារីវប្បកម្ម និង ផែនការដើម្បីផលិត និង កែលំអយ៉ាងទៀងទាត់នូវផែនការដ៏ទូលំទូលាយដើម្បីធ្វើឱ្យមានការគាំទ្រជាក់គិរិត និង រាយការណ៍ពីវិស័យវារីវប្បកម្ម ។ ផែនការទាំងអស់គួរតែបញ្ចូលគ្រប់ចំណុចគាំទ្រដែលពាក់ព័ន្ធ និង ការគ្រប់គ្រងឧស្សាហកម្ម (ឯកសារបន្ថែក១៣.១៤.១៥.១៦.១៧.១៨) ។ ផ្តល់លទ្ធភាពឱ្យមានការចូលរួមពីវារីវប្បកម្ម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ម្ហូបអាហារ និង អភិវឌ្ឍជនបទក្នុងបណ្តាប្រទេសមួយចំនួន វាប្រហែលជាមានប្រយោជន៍ខ្លាំងណាស់ ដើម្បីរៀបចំផែនការអភិវឌ្ឍវារីវប្បកម្មដោយយកចិត្តទុកដាក់ទៅលើផែនការដែលមានស្រាប់ និង កិច្ចខិតខំប្រឹងប្រែង

សំដៅទៅលើសុវត្ថិភាពស្បៀង និរន្តរភាពវារីវប្បកម្ម និង អភិវឌ្ឍជនបទ (ឯកសារបន្ថែម ១៩.២០)។

ការរៀបចំផែនការ និង រាប់បញ្ចូលនូវលទ្ធភាពក្នុងការប្រឹក្សាយោបល់ជាមួយក្រុមដែលធ្លាប់ទទួលប្រយោជន៍ លើកឡើងពីគោលនយោបាយ និង គោលបំណង ការកំណត់ និង អនុវត្តនៃសកម្មភាពផ្សេងៗ ចាំបាច់ត្រួតពិនិត្យការចាត់ចែងរបស់វិស័យ និង កែតម្រូវផែនការអភិវឌ្ឍវារីវប្បកម្ម ។

កិច្ចសហប្រតិបត្តិការល្អរវាងបណ្តាការងារពាក់ព័ន្ធនឹងជួយឱ្យយើងអាចកំណត់នូវប្រភេទនៃទិន្នន័យ និង ព័ត៌មានចាំបាច់សំរាប់ការត្រួតពិនិត្យ និង ធ្វើផែនការ ។

**ប្រអប់ ៤.**

ប្រទេសផ្សេងគ្នាមានការគោរពផ្សេងៗគ្នាទៅលើប្រភពធនធានធម្មជាតិដែលមានស្រាប់ ភាពខុសៗគ្នានៃវារីវប្បកម្ម ដូចជាក្នុងកិរិតអភិវឌ្ឍ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធ ប្រភពធនធានហិរញ្ញវត្ថុដែលមានស្រាប់ ដើម្បីផ្តល់ជាជំនួទានដល់អ្នកជំនាញការ ការអប់រំបណ្តុះបណ្តាល និង ការគាំទ្រផ្សេងៗចំពោះវិស័យហើយពង្រឹងបណ្តាទីផ្សារថ្នាក់មូលដ្ឋាន និង តំបន់ ។ ការសិក្សាវិស័យវារីវប្បកម្មនឹងបង្កើតស្ថានការរបស់វិស័យនិងនិន្នាការរបស់វាជាអ្នកកំណត់ឱកាសនិងភាពស្មុគ្រស្មាញក្នុងក្របខណ្ឌរបស់វា ហើយជ្រើសរើសអត្ថសញ្ញាណ ឬ យុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍ ។ ផ្អែកលើការសិក្សាក្នុងវិស័យយុទ្ធសាស្ត្រសំរាប់វិស័យមួយមិនអាចធ្វើឱ្យរដ្ឋាភិបាលកំណត់ ឬ កំណត់សារឡើងវិញនូវគោលបំណងសំរាប់វិស័យ និង បង្ហាញថាតើធ្វើដូចម្តេចឱ្យគោលបំណងទាំងនេះឆ្លើយតបបានទៅនឹងអត្ថិភាពសកម្មភាពផ្សេងៗ ហើយពណ៌នាពីតំលាតនៃគោលនយោបាយ និង ឧបករណ៍នយោបាយដែលនឹងប្រើដូចជាលក្ខណៈវិនិច្ឆ័យ ដើម្បីបែងចែកដោយឡែកពីគ្នានៃដី និង ទឹក ការផ្លាស់ប្តូរទ្រង់ទ្រាយដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាសមស្រប ។ល។ ផែនការអភិវឌ្ឍវារីវប្បកម្មមួយនឹងដំណើរការផែនការដំណាក់កាលបន្ទាប់ដោយដាក់ចេញជាគោលនយោបាយលំអិតដើម្បីប្រើប្រាស់ធនធានហិរញ្ញវត្ថុ មនុស្ស ធនធានផ្សេងទៀតដែលត្រូវការ និង ក្នុងពេលវេលាដែលផែនការសកម្មភាពនឹងចាប់ផ្តើម ។ ការរៀបចំឡើងនូវឧបករណ៍នយោបាយលំអិតដែលនឹងធ្វើឱ្យ

ហិរញ្ញវត្ថុ មនុស្ស ធនធានចាំបាច់ដ៏ទៃទៀត និង គំរោងពេលវេលាដែលគំរោងផែនការសកម្មភាព និងចាប់ផ្តើមដំណើរការ ។

ផែនការអភិវឌ្ឍវារីវប្បកម្មមួយដែលល្អគួរតែឆ្លុះបញ្ចាំងនូវភាពទទួលខុសត្រូវនៃភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងការអនុវត្តដែលអាចសំរេចដោយអនុលោមទៅតាមគោលការណ៍ និងការណែនាំនានានៃក្រមប្រតិបត្តិ ។ ជាការពិតណាស់ ផែនការអភិវឌ្ឍវារីវប្បកម្មគួរតែសមល្មមទៅនឹងតំរូវការនៃប្រទេសនីមួយៗ ទន្ទឹមនឹងនោះត្រូវយកចិត្តទុកដាក់ដល់លក្ខខណ្ឌសង្គម និង សេដ្ឋកិច្ចដែលនៅក្នុងពេលសកម្មភាពវារីវប្បកម្មកំពុង ឬ នឹងប្រព្រឹត្តិ ។ យន្តការដែលសមស្របសំរាប់ការពិភាក្សារវាងវារីវប្បករ និង អ្នកតំណាងឱ្យវិស័យឯកជនដែលបានចូលរួមចំណែករបស់រដ្ឋអំណាចមូលដ្ឋាន និងសហគមន៍គួរតែត្រូវបានកំណត់ឱ្យបានជាក់លាក់ទៅក្នុងផែនការអភិវឌ្ឍវារីវប្បកម្ម ជាពិសេសយកចិត្តទុកដាក់ទៅលើតួនាទីនៃការអនុវត្ត និង បង្ខំឱ្យមានការអនុវត្តតាមគោលការណ៍ និង សេចក្តីណែនាំនានារបស់ក្រមប្រតិបត្តិ ។

<u>ការធានាភាពរឹងសមស្រប និង ប្រើប្រាស់ធនធានដី និង ទឹកប្រកបដោយភាពទទួលខុសត្រូវ:</u>

គួរតែមានការធានាពីអាជ្ញាធរវារីវប្បកម្ម និង ផែនការដូចជាអ្នកជំនាញខាងវារីវប្បកម្ម និង វិនិយោគិនកំពុងមានសកម្មភាពនៅក្នុងទីតាំងដែល:

- សមស្របសំរាប់និរន្តរភាពនៃផលិតកម្មបង្កើនប្រាក់ចំណូល
- សមស្របទៅនឹងសេដ្ឋកិច្ច និង សង្គម
- ការពារ និង បន្ថយទំនាស់ជាមួយអ្នកប្រើប្រាស់ធនធាននានា ហើយមិនត្រូវបង្កើតឱ្យមានភាពជ្រុលហួសហេតុទៅក្រៅ ។
- គោរពដល់ធនធានបំរុងទុក តំបន់ដែលបានការពារ និង មានសារៈសំខាន់ ឬ ជាពិសេសទីជំរកនានាដែលងាយស្រួលប្រែប្រួល ។

អាជ្ញាធររដ្ឋាភិបាលគួរតែធានាផងដែរនូវសិទ្ធិ និង តំរូវការនៃវិស័យវារីវប្បកម្មដែលបានកត់សំគាល់ និង គោរពដោយអ្នកប្រើប្រាស់ទឹក និង ដីផ្សេងគ្នា ហើយជាពិសេសកសិដ្ឋានវារីវប្បកម្មមិនបញ្ចេញទៅក្រៅបរិស្ថានគំរាមកំហែងដល់សកម្មភាពរបស់វិស័យផ្សេងៗដែលជាហេតុធ្វើឱ្យថយ

ចុះទូវបរិមាណ គុណភាពទឹក ប្រភពចំណីអាហារ និង តំរូវការជីវសាស្ត្រ ។ នៅពេលដែលអាច អនុវត្តទៅបានតំបន់ និង ទីកន្លែងគួរកំណត់ឱ្យបានច្បាស់លាស់ទៅតាមច្បាប់ ដើម្បីបញ្ជាក់ពីតំរូវការ នៃផែនការសំរាប់អភិវឌ្ឍតំបន់ ការគ្រប់គ្រងអាង ទន្លេ ឬ តំបន់ឆ្នេរ និង អាជ្ញាធររបស់គេរៀងៗខ្លួន (ឯកសារបង្អែក ២១,២២,២៣) ។

ដូចដែលបានអនុវត្តទូទៅជាមួយសកម្មភាពកសិកម្ម រុក្ខាប្រមាញ់ វារីវប្បកម្ម និង ជលផលគួរតែយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ ធ្វើឱ្យប្រសើរឡើងផងដែរនូវការងារប្រតិបត្តិទៅក្នុង ផែនការ និង ការគ្រប់គ្រងធនធានទឹកសាប និង ទឹកប្រៃ (ឯកសារបង្អែក២៤-៣៥) ។ ក្នុងប្រទេស ជាច្រើនមានការចាំបាច់ត្រូវសហការ និង ពង្រឹងសមត្ថភាពក្នុងវិស័យជាច្រើនដែលពាក់ព័ន្ធទៅនឹង ផែនការប្រើប្រាស់ធនធានសំរាប់អភិវឌ្ឍវារីវប្បកម្ម រាប់បញ្ចូលទាំងការអនុវត្ត វាយតំលៃប៉ាន់ស្មាន និង វិធីសាស្ត្រត្រួតពិនិត្យធនធាន ធ្វើផែនការគ្រប់គ្រងធនធានដែលប្រើប្រាស់រួមគ្នាច្រើនវិស័យ គណនីបរិស្ថាន យន្តការសំរាប់ដោះស្រាយទំនាស់ និង រួមចំណែកនៃបណ្តាអ្នកដែលមានចំណែកក្នុង ដំណើរការធ្វើសេចក្តីសំរេចចិត្ត ។ អ្នកដែលមានការទទួលខុសត្រូវ និង ទេពកោសល្យពិសេសគួរ តែធ្វើការរួមគ្នា ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់ធនធានដោយគោរពទៅតាមការអភិវឌ្ឍវារីវប្បកម្ម និង វិស័យផ្សេងទៀតបំពេញបន្ថែមឱ្យដល់កំរិតអតិបរមានូវកន្លែងណាដែលអាចសំរេចបាន ។

ឧទាហរណ៍ នៅពេលដែលពិនិត្យ និង អនុវត្តគោលនយោបាយប្រើប្រាស់ធនធានទឹក (ឯកសារបង្អែក៤០) គួរតែយកចិត្តទុកដាក់ដល់ផលប្រយោជន៍ដែលមានស្រាប់ និង ការអភិវឌ្ឍ វារីវប្បកម្ម និង ជលផលទឹកសាបនៅពេលអនាគត ។ ជាពិសេស ការបែងចែកដែនទឹក និង គោល នយោបាយតំលៃគួរតែផ្តោតទៅលើសក្តានុពលសេដ្ឋកិច្ច និង ផលប្រយោជន៍សង្គម កិច្ចសហ ប្រតិបត្តិការវារីវប្បកម្ម និង ជំរុញអនុវត្តការងារប្រតិបត្តិ ។ ទន្ទឹមនឹងនោះ កិច្ចខិតខំប្រឹងប្រែងជា ច្រើនសំដៅទៅលើការអភិរក្សធនធានទឹក និង/ឬ ការពារបរិស្ថាន វារីសត្វអាច និង គួរតែផ្តល់ ប្រយោជន៍ទៅវិស័យជលផល និង វារីវប្បកម្ម ម្ល៉ោះហើយបង្កើនសុវត្ថិភាពស្បៀងអាហារ ហើយ បង្កើនប្រាក់ចំណូលសុទ្ធសំរាប់សហគមន៍មូលដ្ឋាន ឬ ករណីខ្លះ វិភាគទានជាវិជ្ជមានដល់សេដ្ឋកិច្ចនៃ ប្រទេសដែលទទួលអំណោយ ។

**សមត្ថភាពស្ថាប័នដើម្បីគាំទ្រវារីវប្បកម្ម:**

ជាបឋមដើម្បីជាមូលហេតុប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធស្ថាប័នដែលបានប្រើប្រាស់ដោយប្រទេសកំពុងអភិវឌ្ឍ និង គាំទ្រវិស័យវារីវប្បកម្មរបស់គេ ជាទិច្ចកាលរីកចំរើនចេញពីជលផលវុក្ខាប្រមាញ់ ឬ ស្ថាប័នធនធានធម្មជាតិផ្សេងទៀត និង អង្គការនានា ។ ទន្ទឹមនឹងនោះដែរ ប្រទេសទាំងនោះគួរតែបន្តស្វែងរកការចាត់ចែងការងារប្រតិបត្តិ ជាពិសេសយកចិត្តទុកដាក់ចំពោះជីវសាស្ត្រទីផ្សារ និង គុណភាពម្ហូបអាហារ គេក៏គួរតែយកចិត្តទុកដាក់ពង្រឹងចំណងទាក់ទងជាមួយនឹងបណ្តាស្ថាប័នពាក់ព័ន្ធនឹងកសិកម្ម អភិវឌ្ឍជនបទ ធារាសាស្ត្រ វិស្វកម្ម និង វិស័យផ្សេងៗទៀតដែលវារីវប្បកម្មមានសកម្មភាពសាធារណៈ ( ឯកសារបង្អែក៤១.៤២.៤៣) ។ ជាពិសេសកិច្ចសហការរវាងភ្នាក់ងារអភិវឌ្ឍធនធានទឹក និង រដ្ឋបាលវារីវប្បកម្ម និង ជលផលគួរតែបានសំរួលក្នុងការជួយកំណត់លទ្ធផលជាប្រយោជន៍ទូទៅរបស់វិស័យដ៏ទៃទៀត ( ឯកសារបង្អែក ៤៤) ។ អ្នកជំនាញការខាងវារីវប្បកម្ម និង ជលផលគួរតែបានចូលរួមក្នុងការរៀបចំសេដ្ឋកិច្ច និង ឧបករណ៍ច្បាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងទឹក ( ឯកសារបង្អែក៤៥) ។

**ជំរុញឱ្យបានសមស្របការអភិវឌ្ឍ និង បច្ចេកវិទ្យាវារីវប្បកម្ម:**

វាគឺជាការទទួលខុសត្រូវរបស់ប្រទេសនីមួយៗ ដើម្បីធានាថាការអភិវឌ្ឍទាំងអស់សមស្របប្រកបដោយនិរន្តរភាពហើយក្នុងផលប្រយោជន៍សាធារណៈ ។ សកម្មភាពអភិវឌ្ឍវារីវប្បកម្មដែលបានដាក់ស្នើ ជាពិសេសត្រូវតែបានត្រួតពិនិត្យឱ្យជិតដល់នូវទំនាក់ទំនង ក៏រីតបទពិសោធន៍ក្នុងវិស័យនៅប្រទេសមួយចំនួន ។ មន្ត្រីរបស់រដ្ឋាភិបាលសហការជាមួយអ្នកជំនាញការអភិវឌ្ឍវារីវប្បកម្ម និង វិនិយោគិនវារីវប្បកម្មគួរតែវាយតំលៃពីសារប្រយោជន៍ និង ផលវិបាកដែលអាចកើតឡើង រាប់បញ្ចូលទាំងតំលៃនៃការផ្សព្វផ្សាយឱ្យស្គាល់នូវផលិតផលថ្មី ឬ ភាពខុសគ្នានៃផលិតផលវារីវប្បកម្ម វិធី ឬ បច្ចេកវិទ្យាដើម្បីធ្វើឱ្យបានដឹងកាន់តែប្រាកដ ទោះបីគេចង់ធ្វើវិភាគទានក្នុងការបង្កើនផ្គត់ផ្គង់ម្ហូបអាហារ និង អភិវឌ្ឍជនបទ និង/ឬ ដល់សេដ្ឋកិច្ច និង សុខុមាលភាពប្រជាពលរដ្ឋរបស់គេជាទូទៅ ឬ ទោះបីគេទទួលបាននូវលទ្ធផលសំខាន់ជាបន្ទុកសាធារណៈ ដូចជា ការវិនិយោគទុនប្រកបដោយស្មារតីលះបង់ខ្ពស់អ្វីៗដែលតំរូវឱ្យមានដើម្បីឧបត្ថម្ភបំពេញខាត ឬតំរូវការហួសប្រមាណ

លើធនធានដែលកំរ ឬ សំខាន់ (ដី ទឹក វត្ថុធាតុដើមចំណី) ចាំបាច់សំរាប់ផលិតផល និង សកម្មភាពដែលសំខាន់ (ឯកសារបង្អែក ៤៦.៤៧)។ ជាងនេះទៅទៀត អាជ្ញាធរ រដ្ឋាភិបាល និង ស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធត្រូវបានជំរុញមានការយកចិត្តទុកដាក់ដល់សេដ្ឋកិច្ច ឱកាស តំលៃនៃការអភិវឌ្ឍវារីវប្បកម្ម និង ធ្វើការប៉ាន់ប្រមាណ ទោះបីធនធានដែលបានគ្រប់គ្រងអាចប្រើប្រាស់បានជាមួយនឹងការសំចៃ សុខុមាលភាពសេដ្ឋកិច្ចធំជាងទីកន្លែងដទៃទៀត។ យកចិត្តទុកដាក់លើប្រសិទ្ធិភាពតំលៃ និង បែងចែកប្រយោជន៍អាចជួយធ្វើឱ្យកើតមានឡើងនូវការកំណត់គោលបំណងសមស្របនៃផែនការអភិវឌ្ឍវារីវប្បកម្ម។

**"បណ្តាប្រទេសត្រូវធានាថាជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និង ការប៉ាន់ស្មានកន្លែង ដើម្បីនេសាទរបស់គេមិនជះឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍវារីវប្បកម្ម"។**

(ក្រមប្រតិបត្តិ មាត្រា៩.១.៤)

<u>ការធានាការពារជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានៈ</u>

ការពង្រីកផលិតកម្មម្ហូបអាហារនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ ជាពិសេសនៅក្នុងបណ្តាប្រទេសដែលមានឱនភាពនៃចំណូលម្ហូបអាហារអាចជាមធ្យោបាយមួយដំបូង ដើម្បីបង្កើនលទ្ធភាពដែលអាចរកបាននៃម្ហូបអាហារ និង ប្រាក់ចំណូលសំរាប់ការរស់នៅក្នុងភាពក្រីក្រទាំងនោះ។ ជីវភាពរស់នៅរបស់សហគមន៍ជនបទក្នុងតំបន់ទឹកសាប និង ទឹកប្រៃនៃប្រទេសជាច្រើនកំពុងពឹងផ្អែកលើសមត្ថភាពផលិតម្ហូបអាហារនៃជនបទក្រីក្រ តាមរយៈសកម្មភាពជាច្រើនដែលជានិច្ចកាលមានទាំងការប្រតិបត្តិផ្ទុយទៅនឹងកសិដ្ឋានដំណាំលើគោក និង ក្នុងទឹក ការនេសាទ និង ការប្រើប្រាស់ផលិតផលរុក្ខាប្រមាញ់។ ការងារប្រតិបត្តិវារីវប្បកម្មនៅក្នុងតំបន់ជនបទមួយភាគធំ ហើយបានកើនឡើងផងដែរទីតាំងដែលនៅក្នុងចន្លោះទីក្រុងបានបង្ហាញភស្តុតាងនៃការចូលរួមចំណែកជំរុញ និង ឧបត្ថម្ភម្ហូបអាហារឱ្យបានកាន់តែច្រើនមុខ និង បង្កើនប្រាក់ចំណូលនៅក្នុងសហគមន៍មូលដ្ឋានច្រើនថែមទៀត។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើតំរូវការសំរាប់ការប្រតិបត្តិនៃផលិតកម្មម្ហូបអាហារទាំងអស់ ដើម្បីពង្រីកឱ្យកាន់តែខ្លាំងឡើងនូវឯកទេសកម្ម ឬ ធ្វើឱ្យ

មានកាន់តែច្រើនមុខនូវរបៀបប្រតិបត្តិតាមបែបប្រពៃណីដែលមានស្រាប់បាន និង កំពុងបានធ្វើសមាហរណកម្មយ៉ាងល្អក្នុងការបញ្ចូលរបៀបថ្មី (ឯកសារបង្អែក ៤៨)។

វារីវប្បកម្មសំរាប់សហគមន៍ជនបទ:

ចំពោះការងារប្រតិបត្តិវារីវប្បកម្ម ដើម្បីអភិវឌ្ឍប្រកបដោយនិរន្តរភាព និង ដើម្បីជាប្រយោជន៍រួមរបស់សហគមន៍មូលដ្ឋាន វាគឺជាការសំខាន់ណាស់សំរាប់អាជ្ញាធររដ្ឋាភិបាលក្នុងការសំរបសំរួលកិច្ចសហការ និង រៀបចំកសាងនូវកិច្ចសន្ទនារវាងវារីវប្បករ ឬ អ្នករៀបចំវារីវប្បកម្ម និង អ្នកដែលទទួលផលប្រយោជន៍ផ្សេងទៀតក្នុងសហគមន៍មូលដ្ឋាន (ឯកសារបង្អែក៤៩)។ ការថ្លឹងប្រមាណទំហំបរិវេណនេសាទគួរតែត្រូវបានធានារ៉ាប់រង ហើយនៅពេលមានការចាំបាច់ត្រូវដាក់បទបញ្ជាឱ្យបានត្រឹមត្រូវដើម្បីជាប្រយោជន៍ទៅវិញទៅមករបស់ជលផលវារីវប្បកម្មអាស្រ័យជលផល។ រាល់កិច្ចសន្យាគួរតែត្រូវបានជំរុញឱ្យបានចំរើនរវាងវារីវប្បករ និង អ្នកនេសាទដែលមានប្រជាប្រិយភាព ដើម្បីចៀសវាងទំនាស់ការថ្លឹងប្រមាណលើសក្នុងការចែករំលែកធនធាន ដូចជាទឹក លំហរស់នៅរបស់ធនធានវារីសត្វ ។ ការអភិវឌ្ឍវារីវប្បកម្មទ្រង់ទ្រាយធំគួរតែត្រូវបានធ្វើការវាយតំលៃថ្លឹងស្ថានជាមុនពីសង្គម និង សេដ្ឋកិច្ច ដើម្បីកំណត់ការជ្រើសរើសសំរាប់ការចូលរួមចំណែក និង ចែករំលែកប្រយោជន៍ក្នុងចំណោមសមាជិកទាំងអស់របស់សហគមន៍មូលដ្ឋាន និង ដើម្បីធានាការអភិវឌ្ឍទាំងនោះឱ្យសំរេចបាននូវអង្វែងនៃសេដ្ឋកិច្ចជាតិ ។

ប្រទេសទាំងអស់គួរតែរៀបចំវិធានការជាក់លាក់ដែលមានប្រសិទ្ធិភាពចំពោះវារីវប្បកម្ម ដើម្បីទទួលរ៉ាប់រងធ្វើការថ្លឹងស្ថាន និង ត្រួតពិនិត្យបរិស្ថានឱ្យសមស្របទៅនឹងគោលបំណងកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវការប្រែប្រួលអេកូឡូស៊ីដែលមិនល្អ ។

(ក្រមប្រតិបត្តិ មាត្រា៩.១.៥)

ធានាកំរិតផលប៉ះពាល់ទៅលើបរិស្ថានដែលអាចទទួលយកបាន:

ព័ត៌មាន និង វចនាសម្ព័ន្ធគ្រប់គ្រងដើម្បីការពារបរិស្ថានធនធានទឹកសាប និង សមុទ្រត្រូវតែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរុករក និង ព្យាករណ៍នូវការប្រែប្រួលអេកូឡូស៊ីដែលជាលទ្ធផលបណ្តាលមកពីសកម្មភាពមនុស្សនៅក្នុងតំបន់អនុញ្ញាត ។ កិច្ចខិតខំប្រឹងប្រែងធ្វើការថ្លឹងប្រមាណ និង

ត្រួតពិនិត្យផលប៉ះពាល់បរិស្ថានគួរតែត្រូវបានណែនាំដោយមានកំណត់យ៉ាងជាក់លាក់នូវអត្ថិភាពការអភិវឌ្ឍ និង គោលបំណងដែលបានរៀបចំយ៉ាងត្រឹមត្រូវដើម្បីការគ្រប់គ្រងប្រភពធនធាន និង បរិស្ថាន ( ឯកសារបង្អែក ៥០.៥១.៥២.៥៣ ) ។

ជាទូទៅ ទោះជាយ៉ាងណាក៏ដោយក្នុងផលប្រយោជន៍សាធារណៈ កសិករ និង អ្នកប្រើប្រាស់ទឹក អាជ្ញាធររដ្ឋាភិបាលត្រូវតែចាត់វិធានការជាស្រេចសំរាប់ទទួលរ៉ាប់រងធ្វើការប៉ាន់ស្មាន ដើម្បីបង្កើតកសិដ្ឋានវារីវប្បកម្ម ហើយធានាត្រួតពិនិត្យការបង្ហូរទឹក អង្គធាតុរាវជាកាកសំណល់ ការប្រើប្រាស់ថ្នាំពុល ជាតិគីមី និង សកម្មភាពកសិដ្ឋានដែលអាចជះឥទ្ធិពលអាក្រក់ដល់ទឹក និង ដីដែលនៅជុំវិញកសិដ្ឋានឱ្យបានត្រឹមត្រូវ ។ កថាខណ្ឌដែលមានចែងពាក់ព័ន្ធមូលដ្ឋានទិន្នន័យ និង សំរាប់ត្រួតពិនិត្យគួរតែត្រូវបានរៀបចំឡើងធម្មតាក្នុងភាពជាឈ្នាប់ភ្ជាប់ជាមួយវិធានការប្រើប្រាស់ដើម្បីផ្តល់ឱ្យ និង ត្រួតពិនិត្យលិខិតអនុញ្ញាតឱ្យបានម៉ត់ចត់ក្នុងវារីវប្បកម្មលើទីតាំងពិតប្រាកដមួយ ។ ការប៉ាន់ប្រមាណ និង ត្រួតពិនិត្យបរិស្ថានគឺជាផ្នែកមួយយ៉ាងសំខាន់សំរាប់កិច្ចសហការគ្នារវាងអាជ្ញាធរ អ្នកស្រាវជ្រាវ និង វារីវប្បករ ។ ការពិគ្រោះយោបល់គ្នាក្នុងចំណោមភាគីពាក់ព័ន្ធគួរតែធានាថាវិធានការសំរាប់ធ្វើការប៉ាន់ស្មានពីផលប៉ះពាល់បរិស្ថាន និង ត្រួតពិនិត្យគឺសមល្មមហើយរស់រវើកអាចបត់បែនទៅតាមកាលៈទេសៈ ត្រូវចងចាំថា ទំហំខ្នាត និង តំលៃនៃកិច្ចខិតខំប្រឹងប្រែងប្រហែលជាត្រូវលៃដាក់ឱ្យត្រូវទៅតាមទំហំនៃផលប៉ះពាល់ដែលបណ្តាលមកពីដំណើរការវារីវប្បកម្មមួយ ។ នៅពេលណាដែលមានការចាំបាច់ លក្ខណៈវិនិច្ឆ័យគួរតែបានកំណត់ ដើម្បីរៀបចំជាវិធានការសំរាប់ធ្វើការវាយតំលៃ និង ត្រួតពិនិត្យនូវផលប៉ះពាល់ទៅលើបរិស្ថានគួរតែត្រូវបានស្នើឡើងដោយវារីវប្បករ ។ វិធីសាស្ត្រដែលបានដាក់ស្នើសំរាប់ធ្វើការវាយតំលៃប៉ាន់ស្មាន និង ត្រួតពិនិត្យបរិស្ថានគួរតែត្រូវបានវាយតំលៃការអនុវត្តរបស់គេភ្ជាប់ទៅនឹងលក្ខខណ្ឌមូលដ្ឋាន និង ចរិតលក្ខណៈរបស់ទីតាំង ( ឯកសារបង្អែក ៥៤.៥៥.៥៦.៥៧ ) ។

ប្រអប់ ៥:

នៅពេលរៀបចំកម្មវិធី ឬ សំណើផ្សេងៗសំរាប់ធ្វើការវាយតំលៃបាំនស្ទានិង ត្រួតពិនិត្យបរិស្ថាន ដោយគួរតែយកចិត្តទុកដាក់ពិចារណាដល់ភាពខុសគ្នានៃការងារប្រតិបត្តិក្នុងវារីវប្បកម្ម(រួមមានជាពិសេសពូជដែលបានប្រើប្រាស់ និង វិធីសាស្ត្រចិញ្ចឹមដែលបានអនុវត្តកន្លងមក) និងការកំណត់បរិស្ថានរបស់វា ។ ប៉ុន្តែនៅក្នុងករណីជាច្រើន ការសង្កត់ធ្ងន់ជាពិសេសនឹងត្រូវឱ្យផ្តល់នូវភាពងាយស្រួលដែលអាចប្រែប្រួលទៅតាមកាលៈទេសៈ និង ផែលកវាយតំលៃបាំនស្ទាន និង ត្រួតពិនិត្យបរិស្ថាន ដើម្បីសំរបសំរួលនូវការទទួលយក និង ចាប់បង្ខំឱ្យទទួលយកនូវវិធានការទាំងនោះ ។ ការប្រឹក្សាយោបល់ និង ការចូលរួមរបស់ភាគីដែលចូលចិត្ត និង រងឥទ្ធិពលក្នុងការរៀបចំសំណើសំរាប់ការងារវាយតំលៃបាំនស្ទាន និង ត្រួតពិនិត្យបរិស្ថានគួរតែត្រូវបានលើកទឹកចិត្ត ។ ការវាយតំលៃលំអិតមួយពីហិរញ្ញវត្ថុ ធាមពលមនុស្ស និង ពេលវេលាចាំបាច់សំរាប់កិច្ចខិតខំប្រឹងប្រែងគួរតែបានដំណើរការទៅមុខ ទន្ទឹមនឹងការអនុវត្ត ដើម្បីបង្ហាញពីប្រសិទ្ធិភាព តម្លាភាព និង អ្វីដែលអាចធ្វើទៅបាន ។

៣. ការអភិវឌ្ឍវារីវប្បកម្មដែលប្រកបដោយភាពទទួលខុសត្រូវ រាប់បញ្ចូលទាំងវារីវប្បកម្មផ្អែកលើជលផល ក្នុងក្របខណ្ឌដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីនៃវារីសត្វ និង រុក្ខជាតិ

(ក្រមប្រតិបត្តិ មាត្រា ៩.២)

" បណ្តាប្រទេសគួរតែការពារការដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីនៃវារីសត្វ និងរុក្ខជាតិដោយគាំទ្រការងារប្រតិបត្តិវារីវប្បកម្មដែលប្រកបដោយភាពទទួលខុសត្រូវក្នុងក្របខណ្ឌនៃយុត្តាធិការជាតិ និង សហប្រតិបត្តិការក្នុងន័យលើកតំកើងការងារអនុវត្តវារីវប្បកម្មប្រកបដោយនិរន្តរភាព " ។

(ក្រមប្រតិបត្តិ មាត្រា៩.២.១)

<u>ការការពារដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីនៃវារីសត្វ និង រុក្ខជាតិ:</u>

ទន្លេ អាងទន្លេជាច្រើន និង ទីប្រសព្វរបស់វា សមុទ្រក្នុង ឬ សមុទ្រពាក់កណ្តាល បិទជិត ក៏ដូចជាតំបន់ឆ្នេរនានា និង លំហសមុទ្រត្រូវបានចែករំលែកដោយប្រទេសពីរ ឬ ច្រើន ។ វិបាកនៃសកម្មភាពមនុស្សដូចជាការថយចុះនៃទីជំរក និង ការបំពុលទឹកទាំងនេះគឺជានិច្ចកាលតែងទទួលបាន

នូវបទពិសោធន៍នៅក្នុងប្រទេសមួយមិនស្ថិតក្នុងដែនទឹករបស់ខ្លួនដែលនៅខាងក្រោមចរន្តទឹកតាមបណ្តោយទន្លេ ឬ ក្នុងតំបន់ដែលមានដែនទឹកសាប ឬ ទឹកប្រៃធំធេង ។ ឧទាហរណ៍ នៅក្នុងប្រទេសអាជីវកម្មទឹកសាប និងវារីវប្បកម្មផ្អែកលើផលផលមានការខូចខាតបណ្តាលមកពីឱនភាពបរិស្ថាននៃរុក្ខជាតិដែលរស់ឡើងវិញរៀងរាល់ឆ្នាំ និង ទំហំទឹកតាមរដូវ ។ ការប្រែប្រួលគុណភាព និង របបទឹក (ការប្រែប្រួលហួសហេតុ ឬ ការថយចុះនៃកំរិតកំពស់ ទឹក/មាឌ ទាំងទំហំ និង លំហ) ការកែប្រែទ្រង់ទ្រាយនៃទីជំរកត្រីបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើផលផលទឹកសាប ជាពិសេសនៅក្នុងតំបន់ជនបទដែលធ្វើអាជីវកម្មជាលក្ខណៈសិប្បកម្ម និង គ្រប់គ្រាន់តែចិញ្ចឹមជីវិតជានិច្ចកាលតែងតែបរិច្ចាកដើម្បីសុវត្ថិភាពស្បៀងអាហារ ។

មានកិច្ចព្រមព្រៀងអន្តរជាតិជាច្រើនដែលកំពុងនៅជាធរមានបាន និង កំពុងរៀបចំសំដៅការពារបរិស្ថាននៃការដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីរបស់វារីសត្វ និង រុក្ខជាតិ (ឯកសារបង្អែក ៥៨) ។ ប៉ុន្តែនៅពេលដែលការងារប្រតិបត្តិមួយចំនួនក្នុងវារីវប្បកម្ម និង វារីវប្បកម្មអាស្រ័យផលផលអាចមានសក្តានុពលភាពប៉ះពាល់លើការដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីរបស់វារីសត្វ និង រុក្ខជាតិ ប្រសិនបើគ្មានការគ្រប់គ្រងឱ្យបានសមស្រប វាមានសារៈសំខាន់ណាស់ដែលអាជ្ញាធររដ្ឋាភិបាល អ្នកគ្រប់គ្រងផលផល និង វារីវប្បករដឹងពីការប្រថុយប្រថាននៃសក្តានុពលទាំងនោះ ។ ឧទាហរណ៍ អាជ្ញាធរ រដ្ឋាភិបាល វារីវប្បករ និង អ្នកគ្រប់គ្រងផលផលមានកាតព្វកិច្ចពិសេសដើម្បីកាត់បន្ថយការប្រថុយប្រថានក្នុងការផ្សព្វផ្សាយពូជក្រៅស្រុកឱ្យដល់កំរិតអប្បបរមា ឬ ប្រើប្រាស់សន្និធិសេនេទិចបំលែងសំរាប់វារីវប្បកម្ម ឬ វារីវប្បកម្មអាស្រ័យផលផលទៅក្នុងទឹកដែលទីនោះមានការប្រថុយប្រថានបំផុតសំរាប់ការសាយភាយទៅក្នុងទឹកនៃប្រទេសដទៃ ។ ការដាក់ចិញ្ចឹមពូជត្រីពីបរទេស ឬ ពូជក្រៅស្រុកដែលកើតឡើងដោយចៃដន្យ ឬ ដោយចេតនាទៅក្នុងដែនទឹកណាមួយត្រូវតែចៀសវាងចំពោះវិសាលភាពដែលអាចនឹងកើតមានឡើង ប៉ុន្តែនៅពេលដែលយល់ថាសំរាប់គោលបំណងអភិវឌ្ឍវារីវប្បកម្មការសិក្សាដ៏ម៉ត់ចត់អំពីជំរើស និង សក្តានុពលប្រថុយប្រថានមួយគួរតែបានចាប់ផ្តើមជាមុនសិន ។ ក្នុងបរិបទ ឥរិយាបថ និង វិធានការដែលប្រុងប្រយ័ត្នជាមុនគួរតែត្រូវបានជំរុញ ទោះជាសំរាប់ក្នុងស្រុក ឬ ការដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីរបស់

វារីសត្វ និង រុក្ខជាតិ និង កិច្ចសហការប្រតិបត្តិការ ជាពិសេសការផ្លាស់ប្តូរព័ត៌មានរវាងបណ្តាប្រទេសពាក់ព័ន្ធអាចនឹងក្លាយជាវិបត្តិសំរាប់បង្ការការជះឥទ្ធិពលដែលអាក្រក់ ។

<u>ការគាំទ្រ និង សហការប្រតិបត្តិការនិរន្តរភាពវារីវប្បកម្ម:</u>

នៅពេលដែលការទទួលខុសត្រូវរបស់វារីវប្បករត្រូវបានប្រព្រឹត្តិទៅនៅថ្នាក់ជាតិក្រោមរូបភាពជាច្រើនដើម្បីសហការប្រតិបត្តិការនិរន្តរភាពវារីវប្បកម្មក្នុងចំណោមបណ្តាប្រទេសដែលមានការចែករំលែកការដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីរបស់វារីសត្វ និង រុក្ខជាតិ ឧទាហរណ៍ នៅកំរិតអនុតំបន់ ឬ តំបន់។ អាជ្ញាធរ រដ្ឋាភិបាល វិស័យឯកជន សមាគម អ្នកស្រាវជ្រាវ និង អ្នកផ្សេងទៀតនៅក្នុងបណ្តាប្រទេសផ្សេងគ្នាគួរតែស្វែងរក និង ប្រើប្រាស់វា ដើម្បីខិតខំរួមគ្នាដើម្បីជំរុញការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ។ កិច្ចខិតខំទាំងអស់រួមមានការអភិវឌ្ឍ និង ផ្លាស់ប្តូរបច្ចេកវិទ្យា ការអភិវឌ្ឍ និង ការអនុវត្តវិធានការបន្ទាន់នានា ការផ្លាស់ប្តូរព័ត៌មានទីផ្សារ កសាងសមត្ថភាពក្នុងវិស័យវារីវប្បកម្ម អនុវត្តការស្រាវជ្រាវ សេដ្ឋកិច្ចសង្គម និង បញ្ហាបរិស្ថាន។ល។ (ឯកសារបង្អែក ៥៩-៦៥) ។

"បណ្តាប្រទេសគួរតែគោរពបណ្តាប្រទេសជិតខាង និង អនុលោមទៅតាមច្បាប់អន្តរជាតិធានាការជ្រើសរើសពូជប្រកបដោយភាពទទួលខុសត្រូវ កំណត់ទីតាំង និង គ្រប់គ្រងសកម្មភាពវារីវប្បកម្មដែលអាចជះឥទ្ធិពលដល់ការដឹកជញ្ជូនឆ្លងកាត់ដែនប្រព័ន្ធអេកូឡូស៊ីរបស់វារីសត្វ និង រុក្ខជាតិ"។

(ក្រមប្រតិបត្តិ មាត្រា៩.២.២)

<u>ការទទួលខុសត្រូវទូទៅ:</u>

បណ្តាប្រទេសដែលមានសកម្មភាពវារីវប្បកម្មនៅក្នុង ឬ ជាប់ព្រំប្រទល់ដែនទឹកអន្តរជាតិគួរតែទទួលយកនូវកាតព្វកិច្ចចំពោះប្រទេសជិតខាងរបស់គេ ដើម្បីធានាការជ្រើសរើសពូជ ការកំណត់ទីតាំង និង គ្រប់គ្រងសកម្មភាពវារីវប្បកម្មទាំងនោះប្រកបដោយភាពទទួលខុសត្រូវ ។

<u>ការជ្រើសរើសពូជ:</u>

ការជ្រើសរើសពូជសំរាប់វារីវប្បកម្ម និង វារីវប្បកម្មអាស្រ័យជលផលគួរតែផ្អែកលើលក្ខណៈជីវសាស្រ្ត បរិស្ថាន និង សេដ្ឋកិច្ចសង្គមដោយផ្អែកលើធនធានក្នុងតំបន់កាលៈទេសៈ និង ភាពចាំបាច់ ។ វារីវប្បកម្មអាស្រ័យជលផលត្រូវមានការប្រុងប្រយ័ត្នពិសេសជាច្រើន ពីព្រោះគោលបំណងនៃវារីវប្បកម្មគឺផលិតសរីរាង្គមួយដែលរស់នៅក្នុងធម្មជាតិ ។ ប៉ុន្តែវាត្រូវបានកត់សំគាល់ថា សូម្បីតែនៅក្នុងប្រព័ន្ធវារីវប្បកម្មបិទជិតជាទូទៅសរីរាង្គនោះតែងតែគេចរួចចូលទៅក្នុងបរិស្ថាន ។ មានអនុសាសន៍ឱ្យប្រើប្រាស់ពូជវារីសត្វ (fora) ក្នុងស្រុកជាងពូជនាំចូលថ្មី ហើយការប្រើប្រាស់កម្មវិធីបង្កាត់ពូជធម្មតាជាងការបង្កាត់ពូជដោយប្រើបច្ចេកវិទ្យាចម្លងសែនសំរាប់វារីវប្បកម្ម ។រដ្ឋាភិបាលគួរតែដឹងពីធនធានជីវសាស្រ្ត និង សហគមន៍មនុស្សដែលពឹងផ្អែកលើវាដែលអាចជះឥទ្ធិពលដោយសារតែការប្រើប្រាស់សរីរាង្គបញ្ចូលថ្មី ឬ សរីរាង្គសែនដែលបានកែលំអ ។ សក្តានុពល ឬ ផ្លូវនៃការធ្វើឱ្យបែកខ្ញែករាត់រាយទូវពូជវារីសត្វទាំងនោះដែលអាចនឹងកើតមានឡើងគួរតែបានដឹងផងដែរ ។

<u>ការអង្កេតរបាយពូជបញ្ចូលថ្មី:</u>

នៅពេលដែលពូជថ្មីមួយត្រូវបានបញ្ចូលទៅក្នុងប្រទេសមួយ កិច្ចខិតខំរបស់ជាតិគួរតែត្រូវបានធ្វើឡើងដើម្បីត្រួតពិនិត្យ ឬ ទប់ស្កាត់របាយរបស់វា ។ នៅតំបន់ណាដែលមានបរិស្ថានងាយប្រែប្រួលឡាស់មិនគួរអនុញ្ញាតឱ្យចិញ្ចឹមពូជទាំងនោះទេ ឬ តំបន់ដែលមានប្រូបាប៊ីលីតេខ្ពស់អាចឱ្យពូជទាំងនោះងាយគេចចូលទៅក្នុងតំបន់ខ្សែបន្ទាត់ព្រំដែនទឹកមិនគួរអនុញ្ញាតឱ្យធ្វើវារីវប្បកម្មទេ ។ តំបន់ទាំងនោះត្រូវតែបានធ្វើអត្តសញ្ញាណ ហើយរដ្ឋអំណាចមូលដ្ឋាន វារីវប្បករ និង ឧស្សាហកម្មត្រូវតែដឹងទូវដែនកំណត់ធ្វើចលនា និង ការប្រើប្រាស់ ។ ការយកចិត្តទុកដាក់ និង ដែនកំណត់ទាំងនេះគួរតែជាផ្នែកមួយនៃការវាយតំលៃហានិភ័យ និង ការប្រុងប្រយ័ត្នជាមុន ។

<u>ការកំណត់ទីតាំង និង គ្រប់គ្រង:</u>

រដ្ឋាភិបាលគួរតែធានាថា កសិដ្ឋានវារីវប្បកម្មបានកំណត់ទីតាំង និង បានគ្រប់គ្រងទូវផលប៉ះពាល់ទៅលើបរិស្ថាន និង ធនធាននៃប្រទេសដទៃទៀតបានចៀសវាង ។ ជាពិសេសត្រូវមាន

ការប្រយ័ត្នប្រយែងដើម្បីទប់ស្កាត់ការកើតមាននៃជំងឺពាក់ព័ន្ធនឹងពូជវារីវប្បកម្មដែលអាចជះឥទ្ធិពលដល់ធនធានធម្មជាតិ និង ដំណើរការវារីវប្បកម្មក្នុងបណ្តាប្រទេសដទៃទៀត ។ រដ្ឋាភិបាលគួរតែជូនដំណឹងគ្នាទៅវិញទៅមកក្នុងព្រឹត្តិការណ៍នៃការកើតមានជំងឺ epizootic នៃពូជវារីវប្បកម្មដែលទំនងជាបានបញ្ចូនពាសពេញប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ខ្សែបន្ទាត់ព្រំដែនទឹក ហើយធ្វើសហការលើការរៀបចំវិធានការពាក់ព័ន្ធនានាបំរុងទុកក្នុងកិរិតអនុតំបន់ និង តំបន់ ។

"បណ្តាប្រទេសគួរតែប្រឹក្សាយោបល់ជាមួយបណ្តាប្រទេសជិតខាងឱ្យបានសមរម្យ មុននឹងបញ្ចូលពូជដែលមិនមែនអន្តោប្រវេសន៍ទៅក្នុងតំបន់ខ្សែបន្ទាត់ព្រំដែនទឹកនៃប្រព័ន្ធអេកូឡូស៊ីរបស់វារីសត្វ និង រុក្ខជាតិ" ។

(ក្រមប្រតិបត្តិ មាត្រា៩.២.៣)

<u>តួនាទីរបស់ស្ថាប័នជលផលតំបន់:</u>

បណ្តាប្រទេសជិតខាងគួរតែរៀបចំបង្កើតយន្តការ និង វិធានការប្រកបដោយប្រសិទ្ធិភាពសំរាប់ប្រឹក្សាយោបល់ស្តីពីការបញ្ចូលពូជមិនមែនអន្តោប្រវេសន៍ ។ ប៉ុន្តែក្នុងតំបន់ជាច្រើនដែលបានបែងចែកដែនទឹកដោយស្ថាប័នជលផលតំបន់ដែលមានស្រាប់ និង ផ្តល់ពូជវារីសត្វ (fora) ប្រសើរបំផុតសំរាប់ការផ្លាស់ប្តូរព័ត៌មាន ធ្វើកោសល្យវិច័យ និង បុគ្គលិក ។ នៅទីណាដែលគ្មានស្ថាប័នតំបន់ ឬ ការរៀបចំដែលមានស្រាប់នៅទីនោះមានសក្តានុពលបង្កើតមួយ(ឯកសារបន្ថែម៦៦) ។ការប្រឹក្សាយោបល់ពីការបញ្ចូលសរីរាង្គដែលបានកែលំអសែនគួរតែបានធ្វើបន្តផងដែរ ។ និយមន័យនៃមិនមែនអន្តោប្រវេសន៍ក្នុងន័យទូលំទូលាយនៃពាក្យបច្ចេកទេសគួរតែរាប់ទាំងសរីរាង្គដែលជាផលិតផលនៃការផ្សាំង បង្កាត់ ជ្រើសរើសសំរបសំរួលក្រូម៉ូសូម ការបង្កាត់ពូជ ការកែប្រែភេទ និង ការផ្លាស់ផ្ទេរសែន ។ ចំណុចសំរាប់ការប្រឹក្សាយោបល់ និង ផ្លាស់ប្តូររវាងប្រទេសជិតខាងគួរតែរួមបញ្ចូល:

- ពូជ ប្រភពប្រទេស ឬ តំបន់របស់វា និង បរិមាណដែលបាននាំចូល
- កម្មវិធីបង្កាត់ពូជ ឬ ការកែលំអសេនេទិចដែលបានប្រើប្រាស់លើសរីរាង្គ
- ការកំណត់ទីតាំងនៃកសិកម្មវារីវប្បកម្ម និង ផ្លូវនៃការបែងចែកដែលអាចនឹងមាន
- ផលប្រយោជន៍ដែលរំពឹងទុក

-បញ្ហានានាដែលរំពឹងទុក និង សក្តានុពលភាព

- កម្មវិធីត្រួតពិនិត្យ

- ផែនការត្រៀមបំរុង

-ធ្វើរបាយការណ៍ដាក់ជូនទៅអង្គការស្បៀងអាហារ និង កសិកម្មនៃសហប្រជាជាតិ ដើម្បីបញ្ចូលទៅក្នុងតារាងទិន្នន័យ ។

" ប្រទេសទាំងអស់គួរតែបង្កើតយន្តការឱ្យបានសមស្រប ដូចជាតារាងទិន្នន័យ និង ភ្ជាប់បណ្តាញព័ត៌មានសំរាប់ប្រមូលចែករំលែក និង ផ្សព្វផ្សាយទិន្នន័យពាក់ព័ន្ធដល់សកម្មភាពវារីវប្បកម្មរបស់គេដើម្បីសម្របសម្រួលកិច្ចសហការពីផែនការសំរាប់អភិវឌ្ឍវារីវប្បកម្មថ្នាក់ជាតិ អនុតំបន់ តំបន់ និង ពិភពលោកទាំងមូល " ។

( ក្រមប្រតិបត្តិ មាត្រា ៩.២.៤)

<u>ការចែករំលែកព័ត៌មានក្នុងវារីវប្បកម្ម:</u>

ជាពិសេស ក្នុងអំឡុងពេលនៃការរីកចំរើនរបស់វារីវប្បកម្មពិភពលោកយើងនេះ បណ្តាប្រទេស ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងភាគីដែលបានទទួលប្រយោជន៍គួរតែរៀបចំមធ្យោបាយឱ្យបានសមស្រប ដើម្បីត្រួតពិនិត្យសកម្មភាពវារីវប្បកម្មរបស់គេ ហើយរៀបចំសម្របសម្រួលគោលនយោបាយ និង រៀបចំផែនការតាមរយៈការប្រមូលព័ត៌មាន និង ទិន្នន័យពាក់ព័ន្ធទៅនឹងការងារប្រតិបត្តិ និង ការងារផលិតកម្មក្នុងកសិដ្ឋានវារីវប្បកម្មរបស់គេ ការចាត់ចែងសេដ្ឋកិច្ច និង ឥទ្ធិពលវិជ្ជមាន និង អវិជ្ជមានលើសកម្មភាពផ្សេងៗទៀត ។ កិច្ចសហប្រតិបត្តិការជាមួយនឹង ឬ រវាងវារីវប្បករ សមាគមរបស់គេ អ្នកផ្គត់ផ្គង់ អ្នកកែច្នៃ ផលិតផល ពាណិជ្ជករ និង អ្នកផ្តើមគំនិតឯកជនផ្សេងទៀតដែលបានទទួលប្រយោជន៍ពីវិស័យវារីវប្បកម្ម ចាំបាច់ត្រូវតែបានពង្រឹងតទៅទៀតដើម្បីធ្វើឱ្យប្រសើរឡើងនូវទិន្នន័យដែលបានមក និងប្រៀបធៀបការប្រមូល ការវិភាគ ការបកស្រាយ ការចែកផ្សាយ ការប្រើប្រាស់ព័ត៌មាន និង ទិន្នន័យឱ្យបានសមស្រប( ឯកសារបន្ថែក ៦៧) ។ នៅក្នុងប្រទេសជាច្រើន តំរូវការចាំបាច់បន្ទាន់ដើម្បីពង្រឹង ឬ អភិវឌ្ឍ សេវាបណ្ណាល័យឱ្យបានសមស្រប ។ ចរន្តនៃព័ត៌មានដែលពាក់ព័ន្ធនឹងវារីវប្បកម្មក្នុងចំណោមវិស័យ ភ្នាក់ងារ និង អាជ្ញាធរ

ជាច្រើន ទោះបីមានច្រើន ឬ តិចទាក់ទិនជាមួយទិដ្ឋភាពអភិវឌ្ឍវារីវប្បកម្មអាចសម្របសម្រួលបានតាមរយៈការទាក់ទងគ្នាបានគ្រប់ស្ថាប័ន ។ តាមរយៈសកម្មភាពអង្គការតំបន់ និង អន្តរជាតិសមស្របដែលគេទាំងនោះជាសមាជិកប្រទេសទាំងអស់គួរតែចែករំលែកទិន្នន័យពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យតំបន់ និង ពិភពលោកត្រួតពិនិត្យនូវការវិវឌ្ឍន៍ និង បញ្ចាលបាកសម្របសម្រួលគោលនយោបាយ និង អនុញ្ញាតឱ្យព្យាករណ៍ពីកាលៈទេសៈ និង សេចក្តីត្រូវការ (ឯកសារបង្អែក ៦៨) ។

**ប្រអប់ ៦:**

អ្នកប្រើប្រាស់ទិន្នន័យ និង ព័ត៌មានវារីវប្បកម្មទាំងអស់មានលក្ខណៈផ្សេងពីក្នុងធម្មជាតិ និង រួមមានឧទាហរណ៍ វារីវប្បករ អ្នករៀបចំគោលនយោបាយ អ្នកស្រាវជ្រាវ អ្នកធ្វើការ ក្នុងវិស័យម្ហូបអាហារ និង ឧស្សាហកម្មចំណី និង សុខភាពសត្វ អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ អ្នកពាក់ព័ន្ធជាមួយនឹងសុវត្ថិភាពស្បៀងអាហារ ការអភិវឌ្ឍ និង ផែនការធនធាន...។ល។ តំរូវការទិន្នន័យវារីវប្បកម្មសំរាប់ពិភពលោក តំបន់ និង ជាតិកំពុងតែរីកចំរើនឡើងយ៉ាងរហ័ស ។ ជាងនេះទៅទៀត ដើម្បីបន្ថែមទៅលើស្ថិតិផលិតកម្មដែលជាតំរូវការ សំរាប់ទិន្នន័យលើវចនាសម្ព័ន្ធ ចំពោះវិស័យដូចជាតំបន់ស្ថិតក្រោមការធ្វើកសិកម្ម ប្រភេទ និង សមត្ថភាពនៃប្រព័ន្ធផលិតកម្ម ការប្រើប្រាស់ធនធាន (រួមមាន ដី ទឹក សមាសធាតុចំណី ពូជ។ល។) និង ការប្រើប្រាស់ក្នុងវិស័យវារីវប្បកម្ម និង សេវាសម្ព័ន្ធមិត្តរបស់វា ។ ការរីកចំរើនគឺមានប្រយោជន៍យ៉ាងខ្លាំងផងដែរស្តីពីព័ត៌មានក្នុងប្រទេស និង អន្តរជាតិ ចំពោះផលិតផលវារីវប្បកម្ម រាប់បញ្ចូលទាំងការប្រើប្រាស់ជាស្នូល តំលៃផលិតផលពាណិជ្ជកម្ម ឱកាស ទីផ្សារ ។ល។

<u>កិច្ចសហប្រតិបត្តិការតំបន់ក្នុងការផ្លាស់ប្តូរចំណេះដឹងវារីវប្បកម្ម:</u>

វាល់កិច្ចខិតខំប្រឹងប្រែងគួរតែត្រូវបានគាំទ្រដោយរដ្ឋាភិបាល និង ស្ថាប័នដទៃទៀត ឬ ផ្តើមគំនិតដើម្បីជំរុញកិច្ចសហប្រតិបត្តិការ ជាពិសេសនៅថ្នាក់តំបន់ អនុតំបន់ក្នុងការកសាងសមត្ថភាព និង ស្រាវជ្រាវលើប្រព័ន្ធវារីវប្បកម្មដែលសមស្របបំផុតដល់តំបន់របស់គេ ហើយបរិយាយយ៉ាងល្អិតល្អន់នូវយន្តការ និង វិធីការសំរាប់ផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ ជំនួយ

បច្ចេកទេស ដើម្បីគាំទ្រការអភិវឌ្ឍប្រព័ន្ធទាំងនោះឱ្យប្រកបដោយនិរន្តរភាព( ឯកសារបង្អែក ៦៩-៧៤) ។

នៅពេលមានការចាំបាច់ ប្រទេសទាំងអស់គួរតែសហប្រតិបត្តិការគ្នាដើម្បីរៀបចំយន្តការឱ្យបានសមស្របសំរាប់ត្រួតពិនិត្យនូវផលប៉ះពាល់នៃអ្វី១ដែលដាក់បញ្ចូលទៅប្រើប្រាស់ក្នុងវារីវប្បកម្ម ។ (ក្រមប្រតិបត្តិ មាត្រា ៩,២,៥)

<u>សហការធ្វើពាណិជ្ជកម្មស្មើភាពគ្នាលើឧបករណ៍ ចំណី និង អ្វី១ដែលដាក់បញ្ចូលទៅប្រើប្រាស់ក្នុងវារីវប្បកម្ម:</u>

ការជំពាក់បន្តិចបន្តួចដល់តំរូវការនៃឯកទេសកម្មវារីវប្បកម្មដូចជាឧបករណ៍សំភារៈផ្គត់ផ្គង់ និង ការកំណត់បរិមាណដែលមានវត្ថុមានចាំបាច់ ឬ ដែលអាចរកបានក្នុងតំបន់ខ្លះតំរូវការចាំបាច់សំរាប់ជំរុញកិច្ចសហការក្នុងការសម្របសម្រួលកសាងផលិតកម្ម ហើយសំរាប់លើកតំកើងនៃការធ្វើពាណិជ្ជកម្មឧបករណ៍ និង ផ្គត់ផ្គង់នៅក្នុងក្របខ័ណ្ឌ ឬ រវាងបណ្តាតំបន់ ។ ទន្ទឹមនឹងនោះយន្តការនិយ័តករគ្រប់គ្រាន់គួរតែមាននៅនឹងកន្លែង ដើម្បីត្រួតពិនិត្យ និង ធានារ៉ាប់រងឱ្យបានសមរម្យបំផុត និង គុណភាពនៃសំភារៈដែលបានផលិត និង បានធ្វើពាណិជ្ជកម្ម ។ ពាក់ព័ន្ធនឹងវិធានការដែលបានគ្រោងឡើង ដើម្បីការពារជីវិតមនុស្ស វារីសត្វ និង រុក្ខជាតិ ឬ សុខភាព ហើយជាប្រយោជន៍នៃអ្នកប្រើប្រាស់គួរតែគ្មានការប្រកាន់ និង គួរតែអនុលោមទៅតាមក្បួនខ្នាតពាណិជ្ជកម្មអន្តរជាតិដែលបានយល់ព្រមជាគោលការណ៍ ពិសេសសិទ្ធិ និងកាតព្វកិច្ចដែលបានកសាងឡើងនៅក្នុងកិច្ចសន្យារបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ការយកមកប្រើប្រាស់ដើម្បី និង ការផ្លាស់ប្តូរព័ត៌មានលើប្រសិទ្ធិភាព និង សុវត្ថិភាពនៃអ្វី១ដែលដាក់បញ្ចូលទៅប្រើប្រាស់ក្នុងវារីវប្បកម្មគួរតែបានសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ជាតិ តំបន់ និង ពិភពលោក ។

ប្រអប់ ៧:

ប្រទេស និង អាជ្ញាធរនានាមានតួនាទីសំខាន់ដើរតួជាអ្នកកំណត់ និង គាំទ្រសំឡេងដែលទាក់ទងទៅនឹងផលិតកម្មវារីវប្បកម្ម ហើយគួរតែធ្វើសហការជាមួយប្រទេស និង បណ្តាស្ថាប័នអន្តរជាតិ និងអ្នកផ្តួចផ្តើមនានាសំរាប់គោលបំណងទាំងនេះ ។ ប៉ុន្តែពេលខ្លះមានភាពមិនច្បាស់លាស់នូវលក្ខណៈវិនិច្ឆ័យ

សមស្របបំផុតសំរាប់ការនាំចូលបច្ចេកវិទ្យា និង ឧបករណ៍ដែលមានសមត្ថភាពចំណី និង អ្វីៗដែលដាក់បញ្ចូលទៅក្នុងការប្រើប្រាស់ ។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាខ្ពស់ ទោះបី សំរាប់ផលិតកម្មពូជ ឬ ការលូតលាស់ក្នុងកញ្ចប់ ឬ ពូជដែលមិនធ្លាប់ស្គាល់ ឬ សមាសធាតុផ្សេងទៀតដែលមិនធ្លាប់ស្គាល់ ក្នុងករណីខ្លះបានរកឃើញថាធ្វើឱ្យបរាជ័យយ៉ាងរហ័ស ។ប្រសិនបើតំរូវការមួយដែលអាចនឹងកើតមានឡើងសំរាប់នាំចូលគ្រឿងបន្លាស់ ការផ្គត់ផ្គង់ ឬ ធ្វើកោសល្យវិច័យដើម្បីរក្សាប្រព័ន្ធត្រូវបានកំណត់ទាំងនេះអាចគ្មាននិរន្តរភាពសំរាប់រយៈពេលយូរអង្វែង ។ សំខាន់បំផុតគឺការប្រើប្រាស់ពូជក្រៅស្រុក សំរាប់ចិញ្ចឹមគួរតែបានត្រួតពិនិត្យយ៉ាងហ្មត់ចត់បំផុត ប៉ុន្តែអាចធ្វើឱ្យបានត្រឹមត្រូវ ឧទាហរណ៍ ប្រសិនបើ ចង់ធ្វើវិភាគទានដល់សុវត្ថិភាពស្បៀងអាហាររបស់ទាំងនោះគួរតែមានទីផ្សារជាស្រេច ហើយការធ្វើវារីវប្បកម្មក្នុងមូលដ្ឋានប្រព័ន្ធកសិដ្ឋានសមស្របត្រូវបានយល់ច្បាស់ ហើយដែលមិនសមស្របទៅនឹងប្រភេទ និង ពូជក្នុងស្រុក ។

៤.ការប្រើប្រាស់ប្រភពវារីសេនេទិចសំរាប់គោលបំណងនៃវារីវប្បកម្មរាប់បញ្ចូលទាំងវារីវប្បកម្មផ្អែកលើជលផល

(ក្រមប្រតិបត្តិ មាត្រា ៩.៣)

"ប្រទេសទាំងអស់គួរតែថែរក្សានូវភាពផ្សេងៗគ្នានៃសេនេទិច និង បូរណភាពនៃសហគមន៍វារីសត្វក្នុងជាតិ និង ប្រព័ន្ធអេកូឡូស៊ីដោយការគ្រប់គ្រងសមស្រប ។ ជាពិសេស កិច្ចខិតខំប្រឹងប្រែងគួរតែប្រព្រឹត្តិទៅដើម្បីកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវឥទ្ធិពលនៃការផ្សព្វផ្សាយពូជក្រៅស្រុក ឬ សន្និធិសេនេទិចដែលបំលែងបានប្រើប្រាស់សំរាប់វារីវប្បកម្ម រាប់បញ្ចូលទាំងវារីវប្បកម្មអាស្រ័យជលផលទៅក្នុងទឹក ជាពិសេសនៅពេលដែលមានសក្តានុពលសំខាន់ដែលការសាយភាយនៃពូជពីបរទេស ឬ សន្និធិសេនេទិចដែលបានបំលែងទៅក្នុងទឹកក្រោមយុត្តាធិការនៃប្រទេសផ្សេងទៀត ដូចជាទឹកដែលស្ថិតក្រោមយុត្តាធិការនៃប្រទេសដើម ។ នៅពេលដែលអាចធ្វើទៅបាន ប្រទេសទាំងអស់គួរតែជំរុញជាជំហានៗ ដើម្បីកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវសែនមិនសុទ្ធ ជំងឺ និង ឥទ្ធិពលផ្សេងទៀតដែលបណ្តាលមកពីត្រីដែលរួចពីកសិដ្ឋានចិញ្ចឹមទៅក្នុងសន្និធិធម្មជាតិ" ។

(ក្រមប្រតិបត្តិ មាត្រា ៩.៣.១)

ការថែរក្សាភាពផ្សេងគ្នានៃសេនេទិចដោយការងារគ្រប់គ្រង:

ការងារប្រតិបត្តិវារីវប្បកម្មអាចជះឥទ្ធិពលលើពូជដែលមានសេនេទិច សហគមន៍ ប្រព័ន្ធអេកូឡូស៊ី និង ក៏រិតសណ្ឋានដីផ្សេងគ្នា ។ តាមពិតវារីវប្បកម្មបានរៀបចំ ដើម្បីផ្លាស់ប្តូរសណ្ឋានដី និង ប្រព័ន្ធអេកូឡូស៊ីមួយទៅមួយទៀតដែលមានផលិតភាពខ្ពស់ជាង។ ការគ្រប់គ្រងដើម្បីការពារប្រភពសេនេទិចវារីសត្វ និង រុក្ខជាតិចូលរួមពាក់ព័ន្ធដល់ការប្រជុំប្រធាន និង ត្រួតពិនិត្យ (ឯកសារបង្អែក ៧៥) ដូចដែលបានលាតត្រដាងបង្ហាញពីខាងដើម ហើយគួរតែបញ្ចូលនូវឯកសារចាំបាច់នៃប្រភពសេនេទិច "ព្រៃ" ដើម្បីកសាងមូលដ្ឋានគ្រឹះសំរាប់ធ្វើការចាត់ស្មានផលប៉ះពាល់ ។ រាល់កិច្ចខិតខំប្រឹងប្រែងគួរតែត្រូវបានធ្វើឡើងទុកជាឯកសារ ដើម្បីបានប្រើប្រាស់ប្រភពសេនេទិចក្នុងវារីវប្បកម្មដូចជាដើម្បីចងក្រងព័ត៌មានអំពីប្រភពសេនេទិច វារីសត្វ និង រុក្ខជាតិ ។ មូលដ្ឋានព័ត៌មានចាំបាច់ត្រូវអនុញ្ញាតឱ្យកសាងនូវប្រភពសេនេទិចវារីសត្វ រុក្ខជាតិ និង របាយរបស់វារាប់បញ្ចូលទាំងកសិដ្ឋានទាំងអស់ពូជវារីសត្វ និង រុក្ខជាតិក្នុងធម្មជាតិ ។ ជាងនេះទៅទៀតសន្និធិវារីវប្បកម្ម និង សន្និធិសំរាប់វារីវប្បកម្មអាស្រ័យផលផលអាចគ្រប់គ្រងបានក្នុងក្របខ័ណ្ឌឧបករណ៍ និង សំភារៈវារីវប្បកម្ម:

- ចៀសវាងការមិនបង្កាត់ពូជ
- ថែរក្សាបូរណភាពសន្និធិដោយមិនបង្កាត់ចូលគ្នានៃពូជពីសន្និធិ ពូជ ឬប្រភេទផ្សេងគ្នា
- ដោយកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវការផ្លាស់ប្តូរនៃសេនេទិចពីសន្និធិមួយទៅសន្និធិមួយទៀត (មើលខាងក្រោម) និង
- ដោយវាយតំលៃចាត់ស្មានមើលទៅតាមកាលកំណត់នូវភាពខុសគ្នានៃសេនេទិច(គឺ បន្ទប់ពិសោធន៍សំរាប់វិភាគសេនេទិច) ។

កំរិតភាពផ្សេងគ្នានៃសេនេទិចធម្មជាតិអាចថែរក្សាបានដោយសារការកាត់បន្ថយការធ្វើចលនារបស់ប្រជាពលត្រីដែលមានសេនេទិចផ្សេងគ្នាក្នុងក្របខ័ណ្ឌប្រទេសមួយ ។នោះគឺពង/កូនត្រីពូជ/បំលាស់ទីរបស់ត្រីពេញវ័យនៅក្នុងបណ្តាអាងទន្លេ និង ដែនទឹកធំៗគួរតែចៀសវាង ប្រសិនបើអាចធ្វើទៅបាន។ អាងបង្កាត់ភ្ញាស់មានប្រវត្តិបំលាស់ទីរបស់ពងញាស់មានរយៈចំងាយវែង ហើយនេះជាភស្តុតាងដែលបង្ហាញឱ្យដឹងថា មួយភាគធំនៃបំលាស់ទីទាំងនេះមិនបានចាត់ចែងដូចជាសន្និធិក្នុងស្រុកនៅពេលដែល

ដោះលែងទៅក្នុងមជ្ឈដ្ឋានថ្មី ។ ការងារនេះមានសារៈសំខាន់ណាស់ក្នុងវារីវប្បកម្មអាស្រ័យផលផល ។ ក្នុងស្ថានភាពលូតលាស់ដែលជាវដ្តបិទជិត ការបញ្ចូលគ្នានៃសន្និធិសេនេទិចផ្សេងគ្នា ជានិច្ចកាលបានឈានទៅរកវឌ្ឍនភាពនៃការធ្វើវារីវប្បកម្ម ។ ប៉ុន្តែក្នុងករណីនៃពូជកាត់ដែលមិនច្បាស់លាស់ការវិវឌ្ឍន៍ប្រហែលជាអាចរកបានតែក្នុងការបង្កាត់ជំនាន់ដំបូង ហើយមិនមាននៅក្នុងការបង្កាត់ពូជនៃប្រជាពលជំនាន់ក្រោយៗឡើយ ។ បច្ចេកវិទ្យាសែនអាចប្រើប្រាស់បានដែរដើម្បីកាត់បន្ថយភាពប្រថុយប្រថានផលប៉ះពាល់នៃសេនេទិចរបស់កសិដ្ឋានដែលធ្វើសន្និធិក្នុងសន្និធិធម្មជាតិ ។ ឧទាហរណ៍ចិញ្ចឹមសត្វដែលមិនអាចបង្កបង្កើតកូនបាន(ដូចជាស្តេរីល អារ ឬ សរីរាង្គមានភេទតែមួយនៃសរីរាង្គហ្វូងត្រី) នឹងកាត់បន្ថយឱកាសនៃការបង្កាត់ពូជរបស់សរីរាង្គក្នុងធម្មជាតិ ។ ការអប់រំជាសាធារណៈ ស្តីពីសុវត្ថិភាព និង ក្រមសីលធមិនៃបច្ចេកវិទ្យាសេនេទិចប្រហែលជាតំរូវឱ្យមានការធានាឱ្យអ្នកប្រើប្រាស់ទទួលស្គាល់ផលិតផលវារីវប្បកម្ម ។

ពូជក្នុងស្រុកតែងតែត្រូវបានលើកតំកើងជាជំរើសមួយ ដើម្បីផ្សព្វផ្សាយពូជពីបរទេសសំរាប់ការអភិវឌ្ឍវារីវប្បកម្ម ។ ជានិច្ចកាលពូជដែលនាំចូលពីបរទេសមានការនិយមចូលចិត្តពីទស្សនៈសេដ្ឋកិច្ច (ដូចជា មានតំលៃថោក សក្តានុពលសំរាប់ការនាំចេញ។ល។) ហើយពូជក្នុងស្រុកប្រហែលជាមិនអាចផ្សាំងបាន ។

ពូជក្នុងស្រុកអាចមានការនិយមចូលចិត្តពីមូលដ្ឋាន មានឱកាសតិចតួចក្នុងការចំលងជំងឺ ហើយអាចចំបាត់ក្នុងលក្ខខណ្ឌមូលដ្ឋានល្អជាង ។ ប៉ុន្តែពូជក្នុងស្រុកដែលបានយកមកពីក្នុងធម្មជាតិ ហើយត្រូវបានបន្សាំង ឬ ជាកម្មវត្ថុសំរាប់កែលំអសេនេទិចអាចចោទជាបញ្ហាលំបាកខ្លះផងដែរដល់សន្និធិធម្មជាតិដែលនៅសល់រួមមានទាំងទស្សនៈសេនេទិច និង ជំងឺ ។

ប្រអប់ ៨.

យន្តការជាច្រើនដែលមានស្រាប់ត្រូវដាក់កំហិតការប្រើប្រាស់សរីរាង្គដែលបានកែប្រែសេនេទិចហើយបញ្ចូលពូជថ្មីទៅក្នុងវារីវប្បកម្ម ។ ដើម្បីបញ្ចូលពូជថ្មីក្រមប្រតិបត្តិនៃICES/EIFAC(ឯកសារបង្អែក ៧៦.៧៧) សេចក្តីសំរេចស្តីពីការការពារពូជដែលនាំឱ្យវិនាស (USA ឯកសារបង្អែក ៧៨) ក៏ដូចជាច្បាប់ជាតិនៃប្រទេសជាច្រើនទប់ស្កាត់ការប្រើប្រាស់ និង ដឹកជញ្ជូនពូជក្រៅពីពូជធម្មជាតិរបស់គេ ។

សំរាប់សរីរាង្គទូទៅដែលបានកែលំអរួចហើយ (GMOs) តាមបញ្ជារបស់សហគមន៍អឺរ៉ុប (ឯកសារបង្អែក៧៩) ការរៀបចំបទដ្ឋាននានារបស់ USDA (ឯកសារបង្អែក ៨០) ដូចជាក្រមប្រតិបត្តិ ICRS គ្រប់គ្រងការប្រើប្រាស់របស់គេ ការដឹកជញ្ជូន និង លែងត្រឡប់ទៅក្នុងធម្មជាតិ ។ សន្និសីទស្តីពីជីវសាស្ត្រចំរុះបានប្តេជ្ញាចិត្តធ្វើសេចក្តីព្រាងពិធីការសុវត្ថិភាពជីវសាស្ត្រសំរាប់សុវត្ថិភាពនៃការប្រើប្រាស់ប្រភេទសេនេទិចដែលបានកែប្រែហើយ (ផែនការដំបូងនៅក្នុងដំណាក់កាលនេះ) ហើយរហូតដល់ពិធីការនេះត្រូវបានចចារ UNEP ការណែនាំបច្ចេកទេសអន្តរជាតិដើម្បីសុវត្ថិភាពក្នុងបច្ចេកវិទ្យាជីវសាស្ត្រដែលបានផ្តល់អនុសាសន៍ដោយភាគីនានានៃសន្និសីទ (ឯកសារបង្អែក ៨១) ។ មូលដ្ឋានទិន្នន័យ ស្តីពីការបញ្ចូលវារីសត្វអន្តរជាតិ (ឯកសារបង្អែក ៨២) និង ជំងឺវារីសត្វ (ឯកសារ បង្អែក ៨៣) គឺជាប្រភេទព័ត៌មានដែលអាចពិភាក្សា ដើម្បីជួយកំណត់នូវអ្វីដែលជាបញ្ហាស្មុគស្មាញតំរូវឱ្យដាក់ស្នើដូចបានពិភាក្សាខាងដើម ។ មូលដ្ឋានទិន្នន័យទាំងនេះត្រូវបានកែលំអ និង ពង្រីកបន្តទៅទៀត ។

**"បណ្តាប្រទេសគួរតែធ្វើសហប្រតិបត្តិការយ៉ាងរឹងមាំ ក្នុងការយល់ព្រម និង អនុវត្តក្រមប្រតិបត្តិ និងវិធានការផ្សេងៗរបស់អន្តរជាតិសំរាប់ការផ្សព្វផ្សាយ ផ្លាស់ប្តូរសរីរាង្គវារីសត្វ និង រុក្ខជាតិ" ។ (ក្រមប្រតិបត្តិ មាត្រា ៩.៣.២)**

<u>វិធានការ និង ក្រមប្រតិបត្តិអន្តរជាតិផ្សេងៗ:</u>

ក្រមប្រតិបត្តិអន្តរជាតិជាច្រើនដែលមានស្រាប់ កំពុងពាក់ព័ន្ធដល់ការប្រើប្រាស់ពូជផ្សព្វផ្សាយ និង សរីរាង្គដែលបានកែលំអសេនេទិច ហើយត្រូវបានយល់ព្រមក្នុងរូបភាពជាច្រើនដោយសហគមន៍អន្តរជាតិ ។ ក្រមប្រតិបត្តិទាំងនេះជាតំណាងមធ្យោបាយមួយល្អបំផុតក្នុងចំណោមមធ្យោបាយទាំងអស់ ដើម្បីការពារបរិស្ថានវារីសត្វ រុក្ខជាតិ និង ភាពជិតស្និទ្ធនៃសហគមន៍មនុស្សរបស់គេ ។ ក្រមប្រតិបត្តិទាំងនេះផលិតនៅក្នុងបណ្តាប្រទេសអភិវឌ្ឍនៃលោកខាងលិច ។ តំរូវការចាំបាច់ដើម្បីប្រែប្រួលទៅតាមការអភិវឌ្ឍ និង តំបន់ជនបទនៃពិភពលោក ។ សមាសធាតុជាមូលដ្ឋាននៃក្រមប្រតិបត្តិទាំងនេះដូច ICRS រួមមាន:

- ដាក់សំណើដើម្បីផ្សព្វផ្សាយពូជពិសេសមួយក្នុងតំបន់ពិសេសមួយសំរាប់គោលបំណងពិសេសមួយ

- ឯករាជ្យម្ចាស់ការក្នុងការសិក្សាពិនិត្យឡើងវិញនូវសំណើដោយអាជ្ញាធរ រដ្ឋអំណាចដែលមានសមត្ថភាពក្នុងការសិក្សាពិនិត្យឡើងវិញគួរតែរាប់បញ្ចូលការថាំទស្មានបញ្ហាសុក្រស្នាញដែលពិតទាំងអេកូឡូស៊ី សេដ្ឋកិច្ច និង សង្គមផង ។

- បដិសេធ កែសំរួលឡើងវិញ ឬ ទទួលយកសំណើ ។

នៅពេលដែលសំណើផ្សព្វផ្សាយត្រូវបានអនុញ្ញាត រដ្ឋាភិបាលគួរតែសំណូមពរទៅអ្នកជំនាញខាងវារីវប្បកម្មដើម្បី :

- រៀបចំបង្កើតឡើងនូវកម្មវិធីគ្រប់គ្រងសុខភាពត្រីដែលរួមទាំងការថានាការ៉ាបរង និង រោគវិនិច្ឆ័យ

- ត្រួតពិនិត្យ និង វាយតំលៃការជះឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ច និង សង្គម

- ការកត់សំគាល់របស់អង្គការអន្តរជាតិ និង ប្រទេសជិតខាងនានា ។

ទេពកោសល្យនៃប្រទេសមួយ ដើម្បីអនុវត្តបណ្តាសមាសភាពនៃក្រមប្រតិបត្តិត្រូវពឹងផ្អែកលើចំណេះដឹងរបស់សហគមន៍មនុស្ស វារីសត្វ ហិរញ្ញវត្ថុ និង ធនធានមនុស្សដែលមានស្រាប់នៃប្រទេសនោះ ។ ការអង្កេតពីការដាំដុះ ឬ លក់វារីសត្វ និង រុក្ខជាតិនៃប្រព័ន្ធអេកូឡូស៊ីក្នុងស្រុកអាចជួយឱ្យកំណត់នូវពូជក្នុងស្រុកណាខ្លះដែលអាចរងឥទ្ធិពលពីការអភិវឌ្ឍវារីវប្បកម្ម និង ពូជក្នុងស្រុកអ្វីដែលអាចប្រើប្រាស់ជំនួសពូជផ្សាំងនាំចូល ។ ព័ត៌មានពីសេដ្ឋកិច្ច សង្គមលើវិស័យនេសាទ និង ការប្រើប្រាស់ត្រីក៏នឹងជួយកំណត់ផងដែរដល់អ្នកដែលកំពុងទទួលប្រយោជន៍ ឬ រងផលប៉ះពាល់សុក្រស្នាញពីការអភិវឌ្ឍវារីវប្បកម្ម ។ ជាងនេះទៅទៀត ការអង្កេតទីផ្សារអាចជួយកំណត់ប្រសិទ្ធិភាពតំលៃ និង មុខសញ្ញាប្រើប្រាស់សំរាប់បានដាក់ស្នើផ្សព្វផ្សាយ ។

ដើម្បីកាត់បន្ថយឱ្យដល់កំរិតអប្បបរមាបញ្ហាជំងឺឆ្លង និង ឥទ្ធិពលដែលមិនអនុគ្រោះដល់សន្និធិធម្មជាតិ និង វារីវប្បកម្ម ប្រទេសទាំងអស់គួរតែជំរុញលើកទឹកចិត្តឱ្យមានការយល់ព្រមទទួលយកនូវការងារប្រតិបត្តិសមស្របក្នុងការបន្សុតពូជរបស់កូនញាស់ ការផ្សព្វផ្សាយពូជដែលមិននៅក្នុងស្រុក និង ក្នុងផលិតកម្មពូជលក់ និង ដឹកជញ្ជូនពង កូនញាស់ ឬ កូនត្រីម្សៅ កូនត្រីពូជ ឬ

វត្ថុធាតុដើមមានជីវិតដទៃទៀត ។ បណ្ដាប្រទេសគួរតែសំរបសំរួលរៀបចំ និង អនុវត្តក្រមប្រតិបត្តិឱ្យសមស្របទៅនឹងវិធានការ និង ប្រតិបត្តិទៅតាមផែនការឱ្យមានប្រសិទ្ធិភាព ។
( ក្រមប្រតិបត្តិ មាត្រា៩.៣.៣)

<u>ការធានារ៉ាប់រងគុណភាព ទំរង់ការ និង សុវត្ថិភាពអេកូឡូស៊ីរបស់ត្រីពូជ និង កូនត្រីពូជៈ</u>

ប្រទេស និង អាជ្ញាធរវារីវប្បកម្មនានាគួរតែជំរុញការងារប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវក្នុងការបន្សុតពូជ ផលិតកម្មពូជលក់ និង ដឹកជញ្ជូនពង កូនញាស់ ឬ កូនត្រីម្រៀ កូនត្រីពូជ ឬ វត្ថុធាតុដើមដែលមានដើមកំណើតពីវារីសត្វ និង រុក្ខជាតិមានជីវិតដទៃទៀត ។ នៅពេលដែលមានការអនុញ្ញាតឱ្យបន្សុតសែន ការងារប្រតិបត្តិអាងភ្ញាស់ដែលត្រឹមត្រូវចាំបាច់ត្រូវចៀសវាងការធ្វើឱ្យខូចទ្រង់ទ្រាយ ឬ បញ្ហាសេនេទិចផ្សេងទៀតដែលជាបណ្ដាលមកពីការបង្កាត់លើស ។ វាក៏ជាមូលដ្ឋានដើម្បីកាត់បន្ថយឱ្យដល់កំរិតអប្បបរមានៃការសាយភាយចំលងជំងឺ( ឯកសារបង្អែក៨៤.៨៥.៨៦) ។ នៅទីណាដែលសន្និធិពូជធម្មជាតិបានប្រមូលផ្ដុំ និង បែងចែក ជាពិសេសការប្រុងប្រយ័ត្នគឺជាការចាំបាច់ ដើម្បីធានាថាពូជផ្សេងទៀតមិនច្របូកច្របល់ជាមួយសន្និធិដែលចង់បាន( ឯកសារបង្អែក៨៧) ។ ប្រទេសនានាគួរតែរៀបចំសេចក្ដីណែនាំ ឬ បទបញ្ជានានាឱ្យបានសមស្របស្ដីពីការងារប្រតិបត្តិបង្កាត់ពូជ និង បច្ចេកវិទ្យាសែនដែលអាចទទួលយកបាន ។ ឧទាហរណ៍ ប្រទេសមួយចំនួនហាមឃាត់ការបង្កាត់រវាងពូជដែលមិនស្របច្បាប់ ប្រទេសជាច្រើនដាក់លក្ខខណ្ឌផលិតកម្មសរីរាង្គមួយដែលមានការផ្ទេរសែនពីសរីរាង្គមួយផ្សេងទៀត ចំណែកឯការរំលោភបំពានលើច្បាប់ស្ដីពីអាងបង្កាត់ភ្ញាស់ និង សំភារៈចិញ្ចឹមសរីរាង្គមួយដែលមានការផ្ទេរសែនពីសរីរាង្គមួយផ្សេងទៀត ។ ក្រមប្រតិបត្តិអន្តរជាតិបានចែងថាត្រូវបានអនុញ្ញាតឱ្យគំរោងការមួយដើម្បីរៀបចំសេចក្ដីណែនាំ និង វិធានការនានារបស់ជាតិ ។ ដូចដែលបានលើកឡើងពីខាងដើម ប្រទេសនានាគួរតែដាក់កំហិតការប្រើប្រាស់ និង ដឹកជញ្ជូនពូជត្រីដែលបានចិញ្ចឹមតែក្នុងក្របខ័ណ្ឌព្រំដែនប្រទេសរបស់ខ្លួន ។ ប្រទេសទាំងអស់គួរតែជំរុញការប្រើប្រាស់វិធានការឱ្យបានសមស្រប ដើម្បីឱ្យការជ្រើសរើសកូនត្រីពូជ និង ផលិតកម្មពង កូនញាស់ និង កូនត្រីម្រៀ ។
( ក្រមប្រតិបត្តិ មាត្រា ៩.៣.៤)

ការជ្រើសរើសកូនត្រីពូជ:

ការជ្រើសរើសកូនត្រីពូជគួរតែផ្អែកលើទំរង់ត្រីក្នុងវារីវប្បកម្ម កម្មវិធីបង្កាត់ពូជដែលពេញចិត្តទំរង់សែនរបស់ពូជ យកចិត្តទុកដាក់លើសេដ្ឋកិច្ច និង បរិស្ថាន ។ បន្ទាប់ពីការជ្រើសរើសពូជបានសមស្រប ផលិតកម្មពង កូនញាស់ និង កូនត្រីពូជនឹងពឹងផ្អែកលើអាងភ្ញាស់ និង គ្រប់គ្រងការលូតលាស់ ។

ការបង្កាត់ និង បន្សុតសែន:

នៅពេលដែលធ្វើបសិដ្ឋកម្មពូជត្រូវតែគិតពិចារណាធ្វើក្នុងសន្និធិវារីវប្បកម្ម តាមរយៈការជ្រើសរើសសែន និង កម្មវិធីបង្កាត់ពូជវារីវប្បករខ្លះបានស្នើឱ្យមានការបង្កាត់បង្រៀន និង ផ្តល់បទពិសោធន៍ដើម្បីធ្វើការងារប្រកបដោយប្រសិទ្ធិភាពហើយមិនបង្កឱ្យបាត់បង់សែនដែលមានកំលាំងពលំបរិបូណ៌បំផុត ។ សំរាប់មូលហេតុដែលគួរតែធ្វើទាំងនោះគឺត្រូវរៀបចំឧបករណ៍សំភារៈដែលមានលក្ខណៈឯកទេសកម្មសំរាប់អភិវឌ្ឍកែលំអសន្និធិ និង ផលិតកម្មពូជ ។ នៅពេលណាដែលបញ្ហាទាំងនេះមិនអាចអនុវត្តបាន វារីវប្បករគួរតែខិតខំរក្សាទុកសែនដែលមានភាពខុសប្លែកគ្នាឱ្យបានល្អ (ឯកសារបង្អែក ៨៩):

- ដោយបង្កាត់ឱ្យបានកាន់តែច្រើនកាន់តែប្រសើរ
- ដោយប្រើប្រាស់កូនត្រីពូជ និង ពងពីគ្រប់រដូវពងកូនទាំងអស់
- ដោយកត់ត្រាទុកជាឯកសារឱ្យបានហ្មត់ចត់លើចាំវាំមេគ្រផលិតកម្ម ។

កាត់បន្ថយសមត្ថភាពដែលអាចបង្កាត់ភ្ញាស់ កាត់បន្ថយលទ្ធភាពដែលអាចញាស់បង្កើនការខូចទ្រង់ទ្រាយ បង្កើនជំងឺ និង កាត់បន្ថយការរស់នៅអាចជាសញ្ញានៃការមិនបង្កាត់ពូជ និង បាត់បង់ភាពផ្សេងគ្នានៃសេនេទិច ។វាក៏ប្រហែលជាសញ្ញានៃបញ្ហាផ្សេងៗទៀតដែរ ហើយនេះគឺជាអ្វីដែលហៅថាការចុះបញ្ជីល្អចាំបាច់ ដើម្បីកំណត់នូវបញ្ហាចំបងដែលបណ្តាលឱ្យកើតមានឡើង ។ នៅពេលណាដែលអាចធ្វើទៅបាន ប្រទេសទាំងអស់គួរតែគាំទ្រឱ្យមានផងដែរនូវជីវប្រវត្តិបង្កាត់ពូជ និង ប្រវត្តិជំងឺ កាថែរក្សាសំរាប់សន្និធិវារីវប្បកម្ម ។ ការងារនេះវានឹងសំរបសំរួលការផ្លាស់ប្តូរសន្និធិ និង ពូជក្នុង

ក្របខ័ណ្ឌនៃប្រទេស និង ផ្តល់ព័ត៌មានដែលចាត់ទុកថាមានតំលៃ ប្រសិនបើពូជត្រីមួយត្រូវបាន នីហរ័ណ ។

" បណ្តាប្រទេសគួរតែជំរុញការស្រាវជ្រាវនៅទីកន្លែងដែលសមរម្យ និង នៅពេលណាដែលអាចធ្វើទៅបាន អភិវឌ្ឍបច្ចេកទេសចិញ្ចឹមចំពោះពូជត្រីដែលបានរងគ្រោះថ្នាក់ ដើម្បីការពារ ស្តារឡើងវិញ និង ធ្វើឱ្យប្រសើរឡើងនូវសន្និធិរបស់វា ចាំទុកក្នុងចិត្តថាតំរូវការចាំបាច់ដើម្បីអភិរក្សភាពខុសគ្នានៃសេនេទិចរបស់ពូជត្រីដែលបានរងគ្រោះថ្នាក់ "។

(ក្រមប្រតិបត្តិ មាត្រា ៩.៣.៥)

<u>ការការពារពូជត្រីដែលបានរងគ្រោះថ្នាក់:</u>

ការប្រតិបត្តិវារីវប្បកម្មអាចចូលរួមវិភាគទានក្នុងការការពារ និង ធ្វើឱ្យប្រសើរឡើងនូវសន្និធិពូជត្រីដែលបានរងគ្រោះថ្នាក់ ។ប្រទេសនានាគួរតែយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នដល់ខដែលមានចែងក្នុងកិច្ចសន្យាគាំទ្រការអភិវឌ្ឍត្រូវឱ្យបានសមស្របទៅនឹងបច្ចេកទេសចិញ្ចឹមពូជត្រីដែលបានរងគ្រោះថ្នាក់ ។ ការប្រើប្រាស់អាងបង្កាត់ភ្ញាស់ និង ឧបករណ៍វារីវប្បកម្មផ្សេងៗ ដើម្បីការពារជាបណ្តោះអាសន្ន និង ការបង្កាត់ពូជដែលបានរងគ្រោះថ្នាក់គឺត្រូវបានយកចិត្តទុកដាក់ការអភិរក្សក្រៅទីជម្រក ។ នៅពេលដែលការអភិរក្សក្រៅទីជម្រក ជានិច្ចកាលចាំបាច់ត្រូវប្រឈមមុខនឹងបរិស្ថានដែលគំរាមកំហែងបន្ទាន់ និង បាត់បង់សក្តានុពលនៃពូជដែលមានតំលៃ ឬ ប្រភពសេនេទិចវិធីដែលបានចូលចិត្តសំរាប់ការការពារពូជដែលបានរងគ្រោះគឺក្នុងទីជម្រក ដូចជាការស្តារឡើងវិញនូវជម្រក និង ធ្វើឱ្យប្រសើរឡើងនូវពូជដែលបានរងការគំរាមកំហែង ។

<u>ការបង្កាត់ពូជដែលបានរងគ្រោះថ្នាក់:</u>

គោលបំណងនៃកម្មវិធីបង្កាត់ពូជដែលបានរងគ្រោះថ្នាក់គឺដើម្បីផលិតសរីរាង្គដែលអាចលែងចូលទៅក្នុងធម្មជាតិនៅពេលដែលមានការគំរាមកំហែងដល់ការរស់នៅរបស់វាបានត្រូវសម្រាល (ឯកសារបង្អែក ៩០)។ កិច្ចខិតខំបង្កាត់ពូជគួរតែសាកល្បង ដើម្បីបង្កើនឱ្យដល់កំរិតអតិបរមានូវសេនេទិចធម្មជាតិដែលមានលទ្ធភាពអាចផ្លាស់ប្តូរបានក្នុងពូជ:

- ដោយការប្រើប្រាស់ប្រជាពលបង្កាត់ពូជឱ្យកាន់តែទូលំទូលាយកាន់តែប្រសើរ (បង្កើន

ប្រសិទ្ធិភាពទំហំប្រជាពល)

- ចៀសវាងការបង្កាត់នូវសវីវាង្គដែលមានសែនទំនាក់ទំនងគ្នា

-ចៀសវាងការបង្កាត់ពូជ( លើកលែងតែកូនត្រីពូជទាំងពីរភេទមិនអាចរកបានគ្រប់គ្រាន់)

-ចៀសវាង "ការជ្រើសរើសក្នុងប្រទេស" គឺជាការចៀសវាងផលិតសរីរាង្គដែលប្រែប្រួលទៅតាមអាងភ្ញាស់ជំនួសធម្មជាតិ ។

បច្ចេកវិទ្យាសេនេទិចអាចប្រើប្រាស់:

- ដើម្បីធ្វើអត្តសញ្ញាណពូជដែលត្រូវគ្នា ឬ ពូជសមស្រប

- ដើម្បីកំណត់ស្ថានភាពចំណាត់ថ្នាក់នៃពូជដែលបានរងគ្រោះថ្នាក់

-ដើម្បីកសាងឡើងវិញនូវប្រជាពលញី និង ឈ្មោលនៃពូជដែលបានរងគ្រោះថ្នាក់ ការប្រើប្រាស់កាម៉េតពីភេទមួយនៃពូជដែលបានរងគ្រោះថ្នាក់ និង កាម៉េតដែលបានកែលំអនៃភេទផ្សេងទៀតដែលពាក់ព័ន្ធជិតស្និទ្ធ ហើយសន្មតថាពូជមិនទាន់រងគ្រោះថ្នាក់ ។

-ដើម្បីធានាផ្គត់ផ្គង់ជាស្រេចនូវកាម៉េតក្នុងការរក្សាបង្កកទុកនៃស្ពែម៉ាតូស៊ូអ៊ីតពីពូជដែលបានរងគ្រោះថ្នាក់ ឬ ពូជដែលពាក់ព័ន្ធជិតស្និទ្ធ (ខាងលើ) ។

នៅពេលណាដែលអាចធ្វើទៅបាន និងបានដឹងពូជដែលនឹងកើតមានគ្រោះថ្នាក់គួរតែសិក្សា និង គ្រប់គ្រងឱ្យបានដើម្បីកាត់បន្ថយការគំរាមកំហែងនៅក្នុងទីជំរកធម្មជាតិ ។ ក្នុងនាម អ្នកការពារស្ពែម៉ាតូស៊ូអ៊ីត ឬ ឯកត្ត:មានជីវិតគួរតែលៃឱ្យនៅក្រៅទីជម្រក ទទឹមនឹងកិច្ចខិតខំជំរុញឱ្យមានឱកាសល្អសំរាប់ការរស់នៅរបស់វាក្នុងធម្មជាតិ ។ ការជ្រើសរើសពូជនៅក្រៅទីជម្រកសំរាប់ការអភិរក្សគួរតែមិនត្រូវបានគំរាមកំហែងលទ្ធភាពដែលអាចសំរេចបានរបស់ប្រជាពលក្នុងធម្មជាតិ ។

**៥. វារីវប្បកម្មដែលប្រកបដោយភាពទទួលខុសត្រូវនៅក្នុងផលិតកម្ម**

(ក្រមប្រតិបត្តិ មាត្រា ៩.៤)

**"ប្រទេសនានាគួរតែលើកតំកើងវារីវប្បកម្មដែលប្រកបដោយភាពទទួលខុសត្រូវប្រតិបត្តិក្នុងការគាំទ្ររបស់សហគមន៍ជនបទ ផលិតករ អង្គការនានា និង វារីវប្បករ" ។**

<u>ជំរុញការអភិវឌ្ឍវារីវប្បកម្ម:</u>

ការលូតលាស់បានផ្តល់នូវសារៈសំខាន់ក្នុងផលិតកម្ម តំលៃ និង វិសាលភាពនៃវារីវប្បកម្ម និង សកម្មភាពនានាដែលពាក់ព័ន្ធវារីវប្បកម្ម ជាទូទៅ ត្រូវបានគេជឿជាក់ថាវារីវប្បកម្មអាស្រ័យផលផលបានប្រកាន់ខ្ជាប់នូវកិច្ចសន្យាសំរាប់កិច្ចប្រជុំបង្កើនតំរូវការម្ហូបអាហារ ។ តាមពិតវារីវប្បកម្មបានប្រមូលការយកចិត្តទុកដាក់យ៉ាងលើសលប់ក្នុងការអភិវឌ្ឍពិភពលោក ជាពិសេសក្នុងបណ្តាប្រទេសអាស៊ាន ការផ្តល់ចំណីអាហារ និង ចំណូលសេដ្ឋកិច្ចដើម្បីសហគមន៍ជនបទជារឿងសំខាន់ ហើយក្នុងក្របខ័ណ្ឌណាមួយ ប្រសិនបើមានការជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថានដែលធ្លាប់មានបទពិសោធន៍ជាមួយប្រព័ន្ធចំណូលទាបបានសំអិតសំអាងបន្ទុកផលិតកម្មវារីវប្បកម្ម (ឯកសារបង្អែក ៩១.៩២.៩៣) ។ ការនាំចេញនូវពូជដែលមានតំលៃខ្ពស់ រកប្រាក់ចំណូលរូបិយប័ណ្ណបរទេសបានយ៉ាងច្រើនចាំបាច់នៅក្នុងបណ្តាប្រទេសដែលកំពុងរីកចំរើនមួយចំនួន ។ ដែលមានសារៈសំខាន់សំរាប់សុវត្ថិភាពស្បៀងអាហារ ការផលិត កែច្នៃ និង លក់ត្រីផ្តល់ក្តីសង្ឃឹមដើម្បីធ្វើឱ្យប្រសើរឡើងនៃចំណីអាហារនៅជនបទ និង តំបន់ជាយក្រុងដោយលែលកផ្តល់នូវប្រភពប្រូតេអ៊ីនគុណភាពខ្ពស់ដែលមានស្រាប់ ដូចជាផ្តល់ឱកាសដើម្បីបង្កើតចំណូលនៅពេលដែលផលិតកម្មមានច្រើនប្រភេទ ហើយកាត់បន្ថយបញ្ហាស្មុគ្រស្មាញក្នុងការឆ្លើយតបទៅនឹងការផលិតនៃផលិតផលមួយឬច្រើនប្រភេទតែប៉ុណ្ណោះ ។

<u>ជំរុញការងារប្រតិបត្តិ និង ឥរិយាបថដែលប្រកបដោយភាពទទួលខុសត្រូវ:</u>

ក្នុងក្របខ័ណ្ឌនៃប្រទេសមួយចំនួនមាននិន្នាការឆ្ពោះទៅរកការប្រើប្រាស់ប្រព័ន្ធវារីវប្បកម្មបែបប្រពលវប្បកម្ម និង ពូជដែលមានតំលៃខ្ពស់ដែលជាទិច្ចកាលក្នុងតំបន់ឆ្នេរងាយប្រែប្រួលគួរតែបង្កើនសក្តានុពលសំរាប់ការខូចខាតបរិស្ថាន ហើយអាចបូកបញ្ចូលបន្ថែមលើវចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចនៃសហគមន៍មូលដ្ឋាន ប្រសិនបើរបៀបដោះស្រាយអភិវឌ្ឍប្រកបដោយនិរន្តរភាពមិនត្រូវបានយល់ព្រមទទួលយក ។ ដូច្នេះវាជាការចាំបាច់ណាស់ដែលឧស្សាហកម្មវារីវប្បកម្ម និង អ្នកដែលទទួលផលប្រយោជន៍បានចូលរួមយល់ព្រមផ្តល់នូវកិច្ចសន្យាចំមួយសំរាប់កិច្ចសហប្រតិបត្តិការ និង និយ័តកម្មខ្លួនឯង។ សារៈសំខាន់នៃបណ្តាប្រទេស វាគឺជាការទទួលខុសត្រូវនៃប្រទេសនានា ដើម្បីគាំទ្រវារីវប្បករឯកជន និង ឧស្សាហកម្មវារីវប្បកម្ម ជាទូទៅក្នុងការអភិវឌ្ឍនូវបទដ្ឋានរបស់ខ្លួន

សំរាប់ភាពទទួលខុសត្រូវប្រតិបត្តិវារីវប្បកម្ម ។ នៅទីណាដែលមិនទាន់មានប្រទេសគួរតែជំរុញឱ្យមានការរៀបចំសំរាប់ជួយក្រុមកសិករ និង សមាគមផលិតករហើយជំរុញឱ្យប្រសើរឡើងនូវកិច្ចសហការរវាងវិស័យវារីវប្បកម្មឯកជន និង អាជ្ញាធរមូលដ្ឋាន វិទ្យាស្ថានស្រាវជ្រាវ និង ស្ថាប័នអ្នកផលិតម្ហូបអាហារផ្សេងទៀតនៅថ្នាក់មូលដ្ឋាន ជាតិ និង អន្តរជាតិ ។ ធ្វើបែបនេះអាជ្ញាធរ រដ្ឋអំណាចគួរតែបង្កើនការយកចិត្តទុកដាក់លើតំរូវការសិរយាបថដែលប្រកបដោយភាពទទួលខុសត្រូវក្នុងវិស័យវារីវប្បកម្ម ធ្វើរបៀបនេះគឺរឹតតែធ្វើឱ្យមានការកើនឡើងនូវវារីវប្បករនានា និង អ្នកដែលពាក់ព័ន្ធជាមួយវារីវប្បកម្មដែលត្រូវតែបញ្ជាក់ឱ្យមានការទទួលខុសត្រូវលើសកម្មភាពរបស់គេ ។ ការប្រឹក្សាយោបល់ពីការលើកទឹកចិត្តដែលអាចធ្វើទៅបាន ដើម្បីជំរុញការងារប្រតិបត្តិប្រកបដោយភាពទទួលខុសត្រូវអាចរៀបចំឡើងដោយបញ្ចូលអាជ្ញាធររដ្ឋាភិបាល វារីវប្បករ និង សមាជិកសហគមន៍នៅតាមជនបទ ។ ការបំពាក់បំប៉នរយៈពេលខ្លីលើទិដ្ឋភាពនិយ័តកម្មគ្រប់គ្រងការងារប្រតិបត្តិវារីវប្បកម្មគួរតែបានផ្តល់ដល់វារីវប្បករ និង អ្នកដែលពាក់ព័ន្ធរបស់គេ សំរាប់ជួយពួកគេឱ្យធ្វើទៅបាន ដើម្បីចូលរួមក្នុងការរៀបចំ និង ធ្វើឱ្យប្រសើរឡើងនូវនីតិកម្មវារីវប្បកម្មជាក់ស្តែង ។

<u>អត្ថប្រយោជន៍នៃការចូលរួម និង ធ្វើឱ្យត្រឹមត្រូវតាមច្បាប់ដោយខ្លួនឯង:</u>

ផលប្រយោជន៍ចម្បងដែលអាចបានមកពីការចូលរួមក្នុងសមាគមផលិតករ និង ការអភិវឌ្ឍដោយស្ម័គ្រចិត្តរបស់ក្រមប្រតិបត្តិ និង សេចក្តីណែនាំគឺ (ឯកសារបង្អែក ៩៤):

- អ្នកជំនាញវារីវប្បករដែលបានចូលរួមដោយការចុះសំរុងលើបទដ្ឋានទូទៅ និង កម្មវត្ថុក្នុងតួនាទីប្រសើរជាង ដើម្បីការពារផលប្រយោជន៍របស់គេហើយធ្វើការចចារដើម្បីសិទ្ធិ និង ផ្តល់សិទ្ធិប្រឆាំងនឹងការប្រកួតប្រជែងផលប្រយោជន៍ ។

-ចាប់អារម្មណ៍ជាសាធារណៈនៃវិស័យវារីវប្បកម្មអាចជំរុញឱ្យប្រសើរឡើងបានតាមរយៈកិច្ចខិតខំរៀបចំនូវបទដ្ឋាន និង ធ្វើឱ្យបានគ្រប់គ្រាន់ត្រឹមត្រូវតាមច្បាប់ដោយខ្លួនឯង ។

-វានឹងមានការយល់ដឹងជាទូទៅមួយ និង ឯកភាពលើវិធានការជាក់ស្តែងដែលអាច ឬគួរតែបានអនុវត្តដើម្បីធានាការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ។

-តួនាទី និង ការទទួលខុសត្រូវរបស់ក្រុមមនុស្សដែលមានចំណាប់ចំណូលចិត្ត ឬ ស្ថាប័នសាធារណៈ ឬ ឯកជនអាចធ្វើអត្តសញ្ញាណ និង ចចារជាមួយទស្សនៈមួយដើម្បីធានា និង បញ្ជាក់នូវការប្ដេជ្ញាចិត្ត និង ធ្វើវិភាគទានដល់ការអភិវឌ្ឍវារីវប្បកម្មប្រកបដោយនិរន្តរភាព ។

- ជាផ្នែកមួយនៃសមាហរណកម្មគ្រប់គ្រងតំបន់វារីវប្បកម្មដែលប្រកបដោយភាពទទួលខុសត្រូវ ធ្វើតារវៈកិច្ចអន្តរអំពើរបស់វាជាមួយវិស័យផ្សេងទៀតក្នុងកិច្ចអភិរក្ស និង ប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធាន ដូច្នេះអាចស្នើថាវិស័យទាំងនោះមិនធ្វើឱ្យខូចលទ្ធភាពដែលអាចមាននៃធនធាន បរិមាណ និង គុណភាពគ្រប់គ្រាន់បានដាក់ស្នើដោយវារីវប្បកម្ម និង ផលផល ។

" បណ្ដាប្រទេសគួរតែជំរុញការចូលរួមយ៉ាងសកម្មរបស់វារីវប្បករ និង សហគមន៍របស់គេក្នុងការអភិវឌ្ឍប្រតិបត្តិវារីវប្បកម្មប្រកបដោយភាពទទួលខុសត្រូវ " ។

( ក្រមប្រតិបត្តិ មាត្រា ៩.៤.២)

<u>ការចូលរួមជួយឱ្យសំរេចទៅបានៈ</u>

ការិយាល័យរដ្ឋាភិបាល ក្នុងកិច្ចសហការជាមួយអ្នកជំនាញការវារីវប្បកម្ម និង អភិវឌ្ឍជនបទ និង វិស័យពាក់ព័ន្ធផ្សេងទៀតគួរតែស្វែងរក ដើម្បីជំរុញទាំងថ្នាក់ជាតិ និង សហគមន៍សកម្មចូលរួមពីប្រជាកសិករ ឯកជន និង ស្ថាប័ន ផលិតករក្នុងការអភិវឌ្ឍ និង គ្រប់គ្រងនូវរាល់ការងារប្រតិបត្តិវារីវប្បកម្មដែលមានស្រាប់ និង សំរាប់អនាគត ។ ដើម្បីធានាថាការងារប្រតិបត្តិវារីវប្បកម្មដែលបានជ្រើសរើសជំរុញ និង ធ្វើឱ្យប្រសើរឡើងឆ្លើយតបទៅនឹងតំរូវការទូទៅនៃសហគមន៍មូលដ្ឋានដូចដែលលក្ខខណ្ឌនៃបរិស្ថានបានផ្ដល់ទីតាំង ។ ជំបូន្មានដែលផ្ដល់ដោយវារីវប្បករមានបទពិសោធន៍អាចមានសារៈសំខាន់សំរាប់ការជ្រើសរើសទីតាំងបានសមស្រប ពូជ និង ប្រព័ន្ធដូចជា ដើម្បីវិនិច្ឆ័យគំរោងសំរាប់ថែរក្សា និង ដំណើរការរបស់វារីវប្បករហើយគួរតែចាប់អារម្មណ៍ក្នុងការតភ្ជាប់គ្នាជាមួយនឹងតំបន់ និង ទីតាំងដែលបានធ្វើអង្កេត និង នៅកន្លែងដែលសមស្របរៀបចំប្រព័ន្ធព័ត៌មានភូមិសាស្ត្រនៅពេលដែលធ្វើផែនការសំរាប់ប្រើប្រាស់ធនធានក្នុងតំបន់ឆ្នេរ និង ទឹកសាប ។

ព្រមជាមួយគ្នានេះដែរ ផលប្រយោជន៍ និង តម្រូវការនៃសហគមន៍មូលដ្ឋានគួរតែបានធ្វើអត្តសញ្ញាណ នៅពេលដែលធ្វើផែនការសំរាប់ធ្វើសមាហរណកម្ម ឬ ចូលរួមការអភិវឌ្ឍអាចសំរេចទៅបានដោយ ប្រើប្រាស់មធ្យោបាយចាំន់ស្មានជនបទ និង ការចូលរួមសមស្រប (ឯកសារយោង ៩៥.៩៦.៩៧) ។

<u>ការចូលរួមក្នុងស្រាវជ្រាវ:</u>

កិច្ចខិតខំស្រាវជ្រាវសំរាប់វារីវប្បកម្មគួរតែបានផ្តោតលើការជំរុញវិធីចិញ្ចឹមត្រីជាមួយនឹង គោលដៅច្បាស់លាស់លើការអភិវឌ្ឍប្រព័ន្ធវារីវប្បកម្មប្រកបដោយនិរន្តរភាព ចាំទុកក្នុងចិត្តនូវ តម្រូវការដើម្បីបង្កើនការផ្គត់ផ្គង់ស្បៀងអាហារ និង លប់បំបាត់ភាពក្រីក្រ ។ ការបន្តកិច្ចខិតខំប្រឹង ប្រែងគួរតែបានធ្វើឡើង ដើម្បីបញ្ចូលកសិករដែលចិញ្ចឹមវារីសត្វ រុក្ខជាតិ និង សត្វរស់នៅលើគោក សមាគមក៏ដូចជាសហគមន៍របស់គេទៅក្នុងការកំណត់អត្ថិភាពស្រាវជ្រាវ និង ទិសដៅដែលរួមមាន គោលបំណងជាក់លាក់ និង តម្រូវការពិសេសសំរាប់គំរោងការស្រាវជ្រាវ ហើយធ្វើឱ្យការស្រាវជ្រាវរក ឃើញនូវអ្វីសំរាប់បំពេញបន្ថែមដើម្បីពួកគេ (ឯកសារយោង ៩៨.៩៩.១០០) ។

<u>ការបណ្តុះបណ្តាល ផ្សព្វផ្សាយ និង កសាងសមត្ថភាពនៅតាមកសិដ្ឋាន:</u>

តំបន់ជនបទនានានៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ ជាទូទៅបានបំពាក់នូវបច្ចេកទេស ប្រភពហិរញ្ញវត្ថុ និង រចនាសម្ព័ន្ធអប់រំអន់ថយហើយសុវត្ថិភាពរឹងមាំ ហើយបញ្ហាសេដ្ឋកិច្ច និង សង្គមអាចជាលទ្ធផលបណ្តាលមកពីការខ្វះខាតឱកាសរកចំណូល ការអន់ថយនៃប្រព័ន្ធផលិតកម្ម កសិកម្ម និង ថែរក្សារបាយនៃរបស់ប្រើប្រាស់មិនគ្រប់គ្រាន់អ្វីៗដែលប្រើប្រាស់បញ្ចូល និង អ្នកប្រើ ប្រាស់ទំនិញ និង ការកំណត់សកម្មភាពដើម្បីសេវាសាធារណៈ ។ បច្ចេកវិទ្យាសមស្រប និង ទាន់ សម័យទាំងក្នុងការចិញ្ចឹមវារីសត្វ រុក្ខជាតិ និង សត្វរស់នៅលើគោកបានដាក់ស្នើ ដើម្បីជំរុញធ្វើទំនើប កម្មនៃវិធីផលិតកម្មមូលដ្ឋាន ។ ផលប្រយោជន៍ជាច្រើនដែលបានមកពីបច្ចេកវិទ្យាទាំងនោះត្រូវតែស្នើ ឱ្យមានកម្មវិធីបំពាក់បំប៉នអប់រំ និង បង្កើនទេពកោសល្យសំរាប់ធនធានមនុស្សនៅមូលដ្ឋាន ។ប្រទេស នានាគួរតែសាកល្បងបង្កើតវិធី ដើម្បីជួយកសិករ និង សហគមន៍មូលដ្ឋានដោយមានការផ្សព្វផ្សាយ បំពាក់បំប៉ន និង សកម្មភាពកសាងសមត្ថភាពមូលដ្ឋានផ្សេងៗទៀត ។ នៅពេលដែលសកម្មភាព ទាំងនេះមានទ្រង់ទ្រាយតូច ហើយគំលាតឆ្ងាយពីទីប្រជុំជន ការផ្តល់ជំនួយពាក់ព័ន្ធនឹងបញ្ហាទាំងនេះ

មានការលំបាក និង តំលៃខ្ពស់ ។ អាជ្ញាធរវារីវប្បកម្មដែលពាក់ព័ន្ធនឹងវារីវប្បករ និង សហគមន៍របស់គេគួរតែអនុញ្ញាតឱ្យស្វែងរកផលប្រយោជន៍ ដើម្បីធ្វើសហការជិតស្និទ្ធក្នុងការងារផ្សព្វផ្សាយរួមជាមួយកម្មវិធីផ្សព្វផ្សាយកសិកម្មក្នុងតំបន់របស់គេ ធ្វើបែបនេះអាចមានលក្ខណៈប្រសើរជាងហើយត្រូវការបុគ្គលិកច្រើនជាងចំនួនបុគ្គលិកដែលមានស្រាប់ (ឯកសារបង្អែក ១០១, ១០២, ១០៣, ១០៤, ១០៥, ១០៦) ។

<u>ការបិទផ្លាកសញ្ញាដាក់បញ្ចូលប្រើប្រាស់ក្នុងវារីវប្បកម្មៈ</u>

ប្រទេសនានាមានតួនាទីសំខាន់ណាស់ក្នុងការដើរតួជាអ្នកធានា ការនាំចូលឧបករណ៍សំភារៈ ចំណីអាហារ សារធាតុគីមី ។ល។ ដែលប្រើប្រាស់ដោយវារីវប្បករត្រូវបានបិទផ្លាកសញ្ញាត្រឹមត្រូវ ហើយព័តិមានសំខាន់ផ្សេងៗទៀតត្រូវតែបានដាក់បញ្ចូលនូវអ្វីដែលពួកគេ និង សហគមន៍របស់គេមិនសូវបានជួបប្រទះ ។ ភាសាជាតិ និង អ្នកមិនចេះអក្សរគួរតែត្រូវបានយកចិត្តទុកដាក់ ។

<u>ការថែរក្សាឯកសារៈ</u>

